ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

៣. ស. ២៥៦៤ - គ.ស. ២០២០

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

## លេខ ៧

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

" យើងឈ្នះទាំងអស់គ្នា   ហើយឈ្នះជារៀងរហូត
សម្រាប់ជាតិ និង ប្រជាជនកម្ពុជា "

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

១៦ - ១១ - ១៩៩៩

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង
- យឹម ណុលសន

និពន្ធនាយក
- អ៊ីវ ថុង

ការិយាល័យនិពន្ធ
- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋ-កិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត
- ប៉ិច សុខា
- អ៊ិន គុលា

អ្នកចែកផ្សាយ
- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ
- អេង វត្ថមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

**ទំព័រ**

I- វិចារណកថា " កូនខ្មែរត្រូវការសន្តិភាព " ១

II- បទអត្ថាធិប្បាយ "សម្បត្តិវប្បធម៌ខ្មែរ( Les biens culturels Khmers )" ២-៥

III- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តៈ

១- ការពិនិត្យចុងក្រោយលើលិខិតបទដ្ឋានគតិយុត្ត ៦-៨

២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ៩-១០

៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្មទីក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ១១-១២

IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២០ ១៣-២០

V- បទវិភាគៈ

១- បទពិសោធក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយឆ្លើយតបនឹងយេនឌ័រក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា ២១-២២

២- កិច្ចប្រជុំលើកទី ៨ នៃយន្តការសន្ទនារវាងគណបក្សកាន់អំណាចចិន និងរុស្ស៊ី ២៣

VI- សកម្មភាពផ្សេងៗរបស់ថ្នាក់ដឹកនាំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ២៤-៣០

VII- នាទីវប្បធម៌

- ពន្យល់ពាក្យ " ព្រៃ " ៣១-៣៣
- ស្រាវជ្រាវ : យល់ដឹងអំពីពាក្យ " ក្រមសីលធម៌ " ៣៤-៣៥

VIII- នាទីកំណាព្យ

- ឧកញ៉ា ( បទពាក្យ៧ ) ៣៦
- អ្នកមានអ្នកក្រ ( ព្រហ្មគីតិ ) ៣៦

IX- នាទីកំសាន្ត

- រឿងសិង្ហ និង កណ្តុរ ៣៧
- រឿងឆ្លាតគ្រាន់បើ ៣៧

X- ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា ៣៨-៤៣

# កូនខ្មែរត្រូវការសន្តិភាព

*ដោយ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា*

សារលិខិតសម្តេចតេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលនៃកម្ពុជា ដែលបានថ្លែងក្នុងទិវា «សន្តិភាពអន្តរជាតិ» ថ្ងៃទី២១ កញ្ញាកន្លងមកថ្មីៗនេះ បានធ្វើឱ្យយើងទាំងអស់គ្នា ទាំងចាស់ ទាំងយុវជន យុវនារី សម្តែងនូវការដឹងគុណអរគុណសន្តិភាពក្នុងសេចក្តីរីករាយជាទីបំផុត។នេះសរឱ្យឃើញថា«សន្តិភាព»ពិតជាមានគុណតម្លៃណាស់គឺថ្លៃជាងអ្វីៗទាំងអស់សម្រាប់ប្រទេសកម្ពុជាព្រោះពាក្យនេះកំពុងស្ថិតក្នុងសន្តានចិត្ត សតិអារម្មណ៍យើងគ្រប់រូប ចំពោះការចង់រស់នៅដោយភាពសុខដុមរមនា ពីព្រោះប្រទេសនេះធ្លាប់ស្គាល់ ព្រមទាំងរងគ្រោះភ្លើងសង្គ្រាមអស់រយៈពេលប្រមាណមិនតិចជាង៥០០ឆ្នាំកន្លងមក និងស្ទើរបាត់បង់ពីផែនទីពិភពលោក មុនពេលបារាំងចូលមកកម្ពុជាឆ្នាំ១៨៦៣ ហើយពិសេសសង្គ្រាមដែលផ្តើមចេញពីការធ្វើរដ្ឋប្រហារទម្លាក់សម្តេចឪឆ្នាំ១៩៧០ដែលនាំមកនូវការវិនាសអន្តរាយនិងការបាត់បង់ជីវិតមនុស្សជាង២លាននាក់នៅក្នុងរបបមច្ចុរាជឃោរឃៅ ប៉ុល ពត។

ក្នុងសង្គមខ្មែរគ្រប់កាលៈទេសៈ គ្រោះមហន្តរាយដ៏កាចសាហាវកន្លងមក បានក្រាលដោយឈាមទឹកភ្នែក និងគំនរឆ្អឹងរាយប៉ាយស្ទើរក្លាយជាភ្នំគ្រប់ទីកន្លែងនៃផ្ទៃប្រទេស។ បច្ចុប្បន្នស្នាមងងឹតដ៏ខ្មៅចផ្សាពីអតីតកាល បានជំនួសជាស្នាមញញឹមយ៉ាងស្រស់បំព្រងឡើងវិញនៅលើទឹកដីអង្គរដ៏ស្រស់បវរ។ នេះគឺជាបំណងប្រាថ្នារបស់ខ្មែរយើងគ្រប់រូប និងរាជរដ្ឋាភិបាលដោយចង់ឃើញនូវស្នាមញញឹមនេះ ចាក់ឫសជាប់ប្រជាជាតិខ្លួនជារៀងដរាប។ ដូចនេះ ដើម្បីរក្សាបាននូវមរតកសន្តិភាពដ៏ប្រពៃថ្លៃថ្លានេះ គឺយើងចាំបាច់ត្រូវតស៊ូដើម្បីបំបាត់សង្គ្រាមផងដែរ ពីព្រោះគ្មានការរក្សាបានសន្តិភាពណា ដោយពុំមានការប្រុងប្រយ័ត្ននោះទេ។ ហេតុនេះ យើងត្រូវរួមចំណែកឱ្យបានខ្លាំងក្លាបំផុត ក្នុងកិច្ចការពារសន្តិភាព ព្រោះជាបញ្ហារបស់យើងទាំងអស់គ្នា។

ស្ថិតក្នុងបរិការណ៍នេះ កូនខ្មែរទាំងអស់គ្នាគឺជាសសរទ្រូង និងជាគ្រឹះដ៏រឹងមាំសម្រាប់ទ្រសន្តិភាព ដើម្បីបញ្ចៀសសង្គ្រាម។ ចំពោះមុខ យើងត្រូវមានភារកិច្ចទទួលខុសត្រូវខ្ពស់ដើម្បីការពារ កសាងមាតុភូមិជាទីស្នេហារបស់យើង ពីព្រោះទឹកដីនិងប្រជាជាតិដ៏កម្សត់មួយនេះ បានឆ្លងកាត់នូវទុក្ខវេទនានៃសង្គ្រាមរ៉ាំរ៉ៃដែលមិនអាចគណនាអស់។ ហេតុនេះ យើងត្រូវខិតខំរៀនសូត្រ និងស្វែងយល់អំពីមេរៀនប្រវត្តិសាស្ត្រដ៏កម្សត់ពីអតីតកាល រហូតទម្រាំបាននូវសន្តិភាព ការបង្រួបបង្រួមជាតិ និងភាពសុខដុមរមនាពេញលេញដូចពេលនេះ។

ក្នុងស្មារតីនេះ ចំពោះភារកិច្ចដ៏ចម្បងយ៉ាងពិសិដ្ឋរបស់យើងទាំងអស់គ្នា គឺការប្រឆាំងនូវគោលនយោបាយភូតភរ បោកបញ្ឆេតរបស់អ្នកនយោបាយក្លែងក្លាយ ដែលជារឿយៗតែងរុញសង្គម**ឱ្យធ្លាក់ចូលក្នុងវិនាសសកម្មសង្គ្រាម**។ ក្នុងករណីនេះ បើយើងលង់អារម្មណ៍ដោយមិនបានពិចារណាគ្រប់ជ្រុងជ្រោយទៅលើវោហាសាស្ត្រ ឬនយោបាយដែលគ្មានការទទួលខុសត្រូវនោះទេ គឺអាចនាំមកនូវគ្រោះថ្នាក់ដ៏ធំធេងដល់សង្គមជាតិទាំងមូលតែមួយប៉ប្រិចភ្នែក។

យើងទាំងអស់គ្នាត្រូវដឹងថា «សត្រូវសន្តិភាពគឺសង្គ្រាម»។ បានសេចក្តីថា «សន្តិភាពជានគររបស់ព្រះរីឯសង្គ្រាមជានគររបស់មារ»។សព្វថ្ងៃនយោបាយរបស់នគរមារកំពុងបំពុលកូនខ្មែរក្រោមលេសប្រជាធិបតេយ្យនិងសិទ្ធិមនុស្សក្លែងក្លាយដោយសាបព្រួសនូវការបោកបញ្ឆោតបំភ័ន្តមតិកូនខ្មែរ ដោយមូលបង្កាច់គ្រប់មធ្យោបាយ និងគ្រប់រូបភាពដើម្បីប្រឆាំងនឹងនគរព្រះ ក្នុងការសំដៅបំផ្លាញនូវការអភិវឌ្ឍនិងភាពសុខសាន្តសង្គមជាតិ។

យើងជាកូនខ្មែរត្រូវឈ្លាសវៃ ត្រូវស្វែងយល់អំពីមេរៀនពីអតីតកាលដ៏ល្វីងជូរចត់ ពិសេសត្រូវស្វែងយល់អំពីទង្វើនិងផ្នត់គំនិតនយោបាយរបស់នគរមារ«សង្គ្រាម»ដែលជានគរប្រឆាំងនឹងនគរព្រះ«សន្តិភាព»។ បើដូច្នេះ ជានិច្ចកាលយើងត្រូវចោទសួរខ្លួនឯងថា **តើត្រូវធ្វើអ្វីខ្លះ និងមានលទ្ធភាពធ្វើអ្វីខ្លះដើម្បីជាតិ មាតុភូមិយើង មានសន្តិភាពតរៀងទៅជានិរន្តរ៍?**

# សម្បត្តិវប្បធម៌ខ្មែរ ( Les biens culturels Khmers )

ជនជាតិនីមួយៗដែលគេទទួលស្គាល់ថាត្រឹមត្រូវតាមច្បាប់លុះត្រាតែមានពលរដ្ឋមានប្រទេសដែលមានព្រំដែនទឹកដីច្បាស់លាស់ មានប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេសគឺមានវប្បធម៌ផ្ទាល់របស់ខ្លួន។ វប្បធម៌មានភស្តុតាងបិតនៅលើសម្បត្តិវប្បធម៌ ( les biens culturels )។ តើខ្មែរមានវប្បធម៌ឬទេ ? អ្វីខ្លះជាសម្បត្តិវប្បធម៌ខ្មែរ។

វប្បធម៌សម្គាល់អ្វី ដែលផ្តល់ចំណេះដឹងគ្រប់វិស័យទោះបីចេះដឹងតាមផ្លូវកាយ ផ្លូវចិត្ត ផ្លូវបញ្ញា ផ្លូវសម្ភារៈ ដែលមាននៅក្នុងលោកយើងនេះក្តី បរលោកក្តី។ សម្បត្តិវប្បធម៌សម្គាល់កេរដំណែលទាំងឡាយ ដែលផ្តល់ចំណេះដឹងក្នុងអក្សរសាស្ត្រក្តី វិទ្យាសាស្ត្រក្តី តិចនិច ជំនឿ សាសនា សិល្បៈជាដើម។

នានាភាពនៃសម្បត្តិវប្បធម៌ខ្មែរ៖

គេនិយមចែកសម្បត្តិវប្បធម៌ជាពីរផ្នែកគឺ សម្បត្តិវប្បធម៌លទ្ធកម្ម និងសម្បត្តិវប្បធម៌ធម្មជាតិ៖

**១. សម្បត្តិវប្បធម៌លទ្ធកម្ម** ( les biens culturels acquis )

**ផ្នែកអក្សរសាស្ត្រ**

សម្បត្តិវប្បធម៌ខ្មែរមាន៖

-សរសេរលើស្បែកសត្វនៅសម័យហ្វូណន ពីគ.ស.វ.ទី១ ដល់ទី២

-សរសេរលើបន្ទះក្តារ ពីគ.ស.វ.ទី២ ដល់ទី៣

-សរសេរលើសិលាចារឹកនៅវ៉ូកាញ់ខេត្តញ៉ាត្រាង វៀតណាមខាងត្បូងនា ស.វ.ទី៣

-សិលាចារឹកអ្នកតាដំបងដែក ខេត្តតាកែវ គ.ស.វ.ទី៦

-សិលាចារឹកប្រាសាទប្រាំល្វែងនៅកម្ពុជាក្រោម គ.ស.វ.ទី៦

-សិលាចារឹកសម័យចេនឡា គ.ស.វ.ទី៨

-សិលាចារឹកសម័យអង្គរ ពីគ.ស.វ.ទី៩ ដល់ទី១៣

សព្វថ្ងៃនេះយើងមានសាស្ត្រាស្លឹករឹត និងសៀវភៅល្អៗបោះពុម្ពយ៉ាងច្រើនរាប់ពុំអស់។

**ផ្នែកវិទ្យាសាស្ត្រ**

សម្បត្តិវប្បធម៌ខ្មែរផ្នែកនេះពុំមានអ្វីជាដុំកំភួនទេ ព្រោះខ្មែរយើងមើលជំងឺដោយឫសឈើ វល្លិឈើ មើមឈើ សត្វស្រុក សត្វព្រៃ និងមន្តអាគមខ្លះយកតាមគម្ពីរវេទ ប៉ុន្តែខ្មែរចេះគន់គូរដំណើរគោចរព្រះអាទិត្យ ព្រះចន្ទដូចជាគន់គូរសូរ្យគ្រាស ចន្ទគ្រាស...បែបតារាវិទ្យា។ ឯវិទ្យាសាស្ត្រសព្វថ្ងៃជាឥទ្ធិពលរបស់ពួកអឺរ៉ុប។

**ផ្នែកតិចនិក**

ខ្មែរមានសិប្បកម្ម ដូចជាចេះធ្វើកញ្ច្រែង កន្ត្រក បង្គី គោក ត្រុ ទូរទេះ និង របស់ប្រើប្រាស់ផ្សេងៗទៀតសម្រាប់សេចក្តីត្រូវការក្នុងគ្រួសារ។ ខ្មែរចេះស្លដែកតាំងពីសម័យមុនអង្គរ ចេះរំលាយលោហធាតុនៅគ.ស.វ.ទី១១ដូចជាបដិមាព្រះនារាយណ៍ផ្ទំធ្វើអំពីសំរិទ្ធិរើសបានមួយចំហៀងខ្លួននៅបារាយណ៍ខាងលិចយកមកតំកល់ទុកនៅសារមន្ទីរជាតិសព្វថ្ងៃ។

**ផ្នែកជំនឿ**

ខ្មែរមានទំនៀមទម្លាប់ចូលម្លប់ចំពោះកូនស្រី ឯកូនប្រុសត្រូវទៅបួសមុនប្រកបកិច្ចការផ្សេងៗដើម្បីសងគុណឪពុកម្ដាយតាមឥទ្ធិពលនៃសុបិនកុមារ។ ខ្មែរមានប្រពៃណីប្រជាប្រិយ ដូចជាប្រណាំងទូក អាពាហ៍ពិពាហ៍ ត្រុដិសុំទឹកភ្លៀង ជំនឿហោរា។ ខ្មែរមានប្រពៃណីសាសនា ដូចជាបុណ្យភ្ជុំបិណ្ឌ កឋិនទាន បុណ្យផ្កា បំបួសនាគ សំពះព្រះខែ...។

**ផ្នែកសិល្បៈ**

ខ្មែរមានអក្សរសិល្ប៍ប្រជាប្រិយ : ទេវកថា ព្រេងកថា និទានកថា ល្បើក សុភាសិត ពាក្យបណ្ដៅ។ ខ្មែរមានចម្រៀងប្រជាប្រិយ : បទសូរសេះ បទផ្លែបក់កន្ទុយ បទជាត់ជាយ បទសារិកាកែវ បទនគររាជ បទកងសោយ បទដើរព្រៃ បទបេះមន បទបុកស្រូវ បទដកកញ្ចូត បទត្រល់ថ្មី បទខ្មៅបង បទបំពេរ បទទំនួញក្មេងកំព្រា បទជើងសេះ បទលលកស បទស្ដាប់ផ្គរ បទចាបពូក បទកន្សែងក្រហម បទអុំទូក បទត្រពាំងពាយ បទម្លប់ដូង បទផ្កាក្រង បទសុំស្លា បទសុរិយាល្ងាចថ្ងៃ...។

ខ្មែរមានរបាំប្រជាប្រិយ : របាំត្រុដិ របាំក្ងោក របាំទន្សោង របាំប្រើន របាំបេះក្រវាញ របាំឆៃយ៉ាំ របាំកន្ដែររ៉ែ របាំរាំងវង់...។

ខ្មែរមានល្បែងប្រជាប្រិយ : ប្រណាំងទូក ប្រណាំងសេះ ប្រណាំងរទេះគោ ប្រជល់មាន់ ប្រជល់ដំរី ប្រជល់ជ្រូក ប្រជល់គោ ប្រជល់ត្រី បោះអង្គុញ ចោលឈូង លាក់កន្សែង បិតពួន ស្ដេចចង់ អ៊ុ ចោលដំបង វាយឆ្នាំង ទាញព្រ័ត ហ៊ឹង...។

ខ្មែរមានកីឡា : ចំបាប់ ប្រដាល់សេរី ( មានក្បាច់រំលឹកគុណគ្រូដូចជា ទន្សាយប្រឡែងព្រះច័ន្ទ ព្រហ្មមុខបួន ព្រះរាមព័ទ្ធសីមា នាគលេងទឹក ហនុមានសំដែងឫទ្ធិ ព្រះរាមផ្លែងសរ ស្រងៃពេន ខ្លាក្រាប...) ល្បុក្កតោឬបុកកាតោ សី កូនគោល។

ខ្មែរមានរបាំបុរាណដូចជារបាំអប្សរា របាំទេពនោរម្យ របាំមណីមេខលា របាំកាប់ក្របីផឹកស្រា របាំអាយ៉ៃ របាំប្រកកែ របាំក្ងួនបុប្ផា ផ្សំនឹងតន្ត្រីយ៉ាងច្រើន។

ខ្មែរមានភ្លេងប្រជាប្រិយ ភ្លេងការ ភ្លេងមហោរី ភ្លេងពិណពាទ្យ ភ្លេងខ្លងខែក...។ ឧបករណ៍វង់ភ្លេងខ្មែរមាន ដូចជារនាតឯក រនាតដែក រនាតធុង ទ្រខ្មែរ ទ្រអ៊ូ ទ្រសោ ទ្រឆេ តាខេ ខ្លុយ ស្គរ សម្ភោរឬស្គរមុខពីរ ប៉ីកែវ ប៉ីបបុស ប៉ីអ ប៉ីពក ស្រឡៃ គងធំ គងតូច ចាប៉ី ឆៃយ៉ាំ ក្រាប ឈឹង សាយដៀវ ឃឹម...។

ខ្មែរមានល្ខោននិយាយ ល្ខោនបាសាក់ ល្ខោនខោល ល្ខោនគ្រាប់ ណាំងស្បែក យីកេ និង រហ័សកម្ម។ ឆៃយ៉ាំច្រើនលេងនៅចន្លោះឆាកល្ខោននីមួយៗដើម្បីបង្កើតបរិយាកាសរីករាយ។ម្យ៉ាងទៀតគេច្រើនយកឆៃយ៉ាំជាមធ្យោបាយទាក់ទាញសប្បុរសជនឱ្យចូលបច្ច័យជាសទ្ធាជ្រះថ្លាពេលបុណ្យផ្កាបុណ្យកឋិនបុណ្យបំបួសនាគ។ ខ្មែរមានទម្លាប់មួយយ៉ាងសំខាន់គឺ ខ្មែរចូលចិត្តឆ្លាក់តាំងពីជញ្ជាំងប្រាសាទ ខ្លោងទ្វារ ហោជាង ផ្ដែ បង្កាន់ដៃ ព្រោះខ្មែរពុំចូលចិត្តឃើញផ្ទៃទំនេរជាការបញ្ជាក់ថាខ្មែរ ឧស្សាហ៍ ព្យាយាម ស្វិតស្វាញ ម៉ត់ចត់។

ខ្មែរមានស្ថាបត្យកម្មយ៉ាងច្រើន បានកសាងប្រាសាទរាប់រយពាន់ សម្រាប់ឧទ្ទិសទៅសាសនា។ ស្ថាបត្យកម្មទាំងនោះមានចែកតាមរចនាបថទាំង១៣ ៖ ភ្នំដា សំបូរព្រៃគុក ព្រៃក្មេង កំពង់ព្រះ គូលែន ព្រះគោ បាខែង កោះកេរ បន្ទាយស្រី ឃ្លាំង បាពួន អង្គរវត្ត និងបាយ័ន។

ការតុបតែងខ្លួនរបស់ស្ត្រីខ្មែរគឺធ្វើឲ្យធ្មេញខ្មៅ ដែលចាប់ផ្ដើមអនុវត្តក្រោយពេលចូលម្លប់ ឬនៅក្រោយអាពាហ៍ពិពាហ៍។ ខ្មែរនិយមធ្មេញខ្មៅតាំងពីសម័យមុនអង្គរមកម្ល៉េះ ហើយសព្វថ្ងៃនេះ ខ្មែរនៅនិយមខ្លះដែរ ដូចជាស៊ីស្លាម្លូដើម្បីឱ្យបានធ្មេញខ្មៅពេលក្រោយអាពាហ៍ពិពារហ៍ចំពោះគ្រួសារអ្នកស្រែ។នៅទីក្រុងការនិយមស៊ីស្លាម្លូមានចំនួនតិចណាស់ ប៉ុន្តែនៅមានជីវិតនៅឡើយ។

ការរៀបរាប់មកខាងលើនេះ សុទ្ធសឹងជាសម្បត្តិវប្បធម៌លទ្ធកម្ម ដែលជាសម្បត្តិវប្បធម៌មនុស្សខ្មែរកសាងឡើង មនុស្សខ្មែរខំសន្សំបន្តិចម្តងៗ ប្រមូលពីនេះបន្តិច ពីនោះបន្តិច កែច្នៃឲ្យបានជាសម្បត្តិវប្បធម៌ឡើង។

**២. សម្បត្តិវប្បធម៌ធម្មជាតិ** ( les biens culturels naturels )

ដែលហៅថាសម្បត្តិវប្បធម៌ធម្មជាតិរបស់ជនជាតិនីមួយៗគឺជាភោគទ្រព្យទាំងឡាយនិងអ្វីៗទាំងអស់ ទោះរូបីក្តី អរូបីក្តី ដែលកើតតាមធម្មជាតិមក ផ្ទុយពីសម្បត្តិវប្បធម៌លទ្ធកម្មដែលមនុស្សកសាងបង្កើតឲ្យមានឡើង។

សម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរមានច្រើន ៖

- ព្រំដែនទឹកដីខ្មែរ
- សមុទ្រខ្មែរ
- ទន្លេ ស្ទឹង បឹងបួ ស្រះ ត្រពាំងរបស់ខ្មែរ
- ភ្នំទាំងឡាយរបស់ខ្មែរ ដូចជាភ្នំដងរែក ភ្នំក្រវាញ ភ្នំគូលែន ភ្នំបូកគោ ភ្នំពពកវិល ភ្នំខ្មោច ភ្នំប្រុស ភ្នំស្រី ភ្នំជីសូរ ភ្នំស្រង់ ភ្នំពេជ្រនិល ភ្នំគិរីរម្យ ភ្នំកំចាយ ភ្នំទំពរ ភ្នំក្រចៅ ភ្នំសំកុស ភ្នំធំ ភ្នំទឹកព្រិល ភ្នំសំពៅ ភ្នំក្រពើ ភ្នំថ្មកែស ភ្នំស្វាយ ភ្នំសន្ទុក ភ្នំគិរីវង្ស ភ្នំក្រោម...
- កោះខ្មែរក៏មានច្រើនណាស់ដែរ ដូចជាកោះត្រល់ ( ត្រូវគេយកនៅគ.ស. ១៩៤៩ ) កោះទន្សាយ កោះត្បាល់ កោះពោធិ កោះអង្រ្កង កោះសេះ កោះថ្មី កោះស្រមោច កោះឫស្សី កោះតាគារ កោះច្រឡុស កោះពស់ កោះកោងកាង កោះរុង កោះរុងសំឡឹម កោះឌុយកូន កោះសីណាល់ កោះកណ្តាល កោះស្នាច់ កោះសាមិត កោះកុង កោះម្ទូល កោះតាង ...
- ឆ្នេរខ្សាច់ខ្មែរមានឆ្នេរខ្សាច់កែប កំពង់សោម កំពង់សិលា
- រុក្ខជាតិរបស់ខ្មែរមានដើមត្នោត ដែលអាចមានអាយុជាងមួយរយឆ្នាំ ដើមដូង ដើមធុរេន ដើមកៅស៊ូ ដើមស្វាយ ដើមគ្រញូង ដើមបេង ដើមនាងនួន ដើមឈើទាល ដើមស្រឡៅ ដើមធ្នង់ ដើមម៉ៃសាក់ ដើមគគីរ ដើមដូងចែម ដើមកកោះ ដើមក្រឡាញ់ ដើមស្រូវ... ដែលសុទ្ធសឹងជាសម្បត្តិវប្បធម៌ផ្តល់ប្រយោជន៍សេដ្ឋកិច្ចឲ្យខ្មែរ
- ក្រៅពីនេះខ្មែរនៅមានសត្វស្រុក សត្វព្រៃ មច្ឆាជាតិយ៉ាងច្រើន ដែលខ្មែរត្រូវអភិវឌ្ឍនិងអភិរក្សដើម្បីវិស័យទេសចរណ៍ឬអាចបញ្ជូនទៅលក់នៅបរទេសទៀតផង
- សម្បត្តិវប្បធម៌ធម្មជាតិសំខាន់ជាងគេគឺមនុស្សខ្មែរ ព្រោះមនុស្សខ្មែរនេះហើយជាអ្នកការពារសម្បត្តិវប្បធម៌ទាំងអស់របស់ខ្មែរ មនុស្សខ្មែរតំណាងអរិយធម៌ខ្មែរ ដោយនៅក្នុងខ្លួនមនុស្សខ្មែរមានព្រលឹងខ្មែរ នៅក្នុងព្រលឹងខ្មែរមានខ្លឹមខ្មែរ។ ហេតុនេះ ត្រូវរក្សាមនុស្សខ្មែរឲ្យគង់វង់ ត្រូវចៀសវាងសង្គ្រាមសម្លាប់ខ្មែរគ្នាឯង។ ការបាត់បង់ជីវិតនៃពលរដ្ឋខ្មែរ គឺជាការវិនាសនៃសម្បត្តិវប្បធម៌ធម្មជាតិរបស់ខ្មែរ ក៏ដូចជាការវិនាសនៃព្រលឹងខ្មែរ។

៣. តើត្រូវធ្វើដូចម្ដេចដើម្បីថែរក្សាសម្បត្តិវប្បធម៌?

**ចំពោះសម្បត្តិវប្បធម៌លទ្ធកម្ម៖**

-គួរកសាងសមិទ្ធិឲ្យបានច្រើន ទោះបីក្នុងវិស័យ អក្សរសាស្ត្រ វិទ្យាសាស្ត្រ តិចនិច សិល្បៈ ជំនឿ សាសនា...

-បណ្ដុះគំនិតស្នេហាវប្បធម៌ជាតិ ប៉ុន្តែមិនត្រូវបណ្ដុះគំនិតស្អប់វប្បធម៌ជាតិដទៃ ត្រូវទទួលស្គាល់វប្បធម៌បរទេសណា ដែលអាចនាំមកនូវការរីកចម្រើនដល់ជនជាតិរបស់ខ្លួន ព្រមទាំងចៀសវាងការអួតអាងវប្បធម៌ជាតិរបស់ខ្លួនហួសហេតុ

-ផ្សព្វផ្សាយវប្បធម៌ជាតិ

**ចំពោះសម្បត្តិវប្បធម៌ធម្មជាតិ៖**

-ត្រូវថែរក្សាព្រំដែនទឹកដីខ្មែរឲ្យបានគង់វង់

-ត្រូវថែរក្សារុក្ខជាតិ ព្រៃឈើ សត្វស្រុក សត្វព្រៃ មច្ឆាជាតិ កុំឲ្យវិនាសហិនហោចឥតប្រយោជន៍

-ចៀសវាងសង្គ្រាមសព្វបែបយ៉ាង

-កុំសម្លាប់ខ្មែរគ្នាឯងផុយពេកប៉ុន្តែមិនត្រូវអត់អោនដល់អ្នកសម្លាប់ជីវិតគេទេដើម្បីចៀសវាងកុំឲ្យអ្នកក្រោយយកតម្រាប់តាម។ការសម្លាប់ខ្មែរគ្នាឯងគឺជាគុណវង្វាន់របស់ប្រទេសជិតខាងព្រោះកាលណាប្រជាជនខ្មែរកាន់តែមានចំនួនតិចទៅៗ យើងនឹងក្លាយទៅជាជនជាតិភាគតិច ដូចមានឧទាហរណ៍នៅកម្ពុជាក្រោមសព្វថ្ងៃ។សភាបារាំងចុះហត្ថលេខានៅថ្ងៃទី២១ឧសភា១៩៤៩ប្រគល់ទឹកដីកម្ពុជាក្រោមឲ្យទៅយួនខាងត្បូងក៏ព្រោះតែឃើញពលរដ្ឋខ្មែរនៅកម្ពុជាក្រោមមានចំនួនតិចជាងយួនច្រើនពេក។នេះជាកលល្បិចរបស់យួនដែលបានបោកប្រាស់ខ្មែរឲ្យរត់ពួនពេលបារាំងទៅពិនិត្យមើលដល់ទីកន្លែង។គួរកុំឲ្យព្រឹត្តិការណ៍បែបនេះកើតឡើងម្ដងទៀត ប៉ុន្តែព្រឹត្តិការណ៍នេះកំពុងលេចរូបរាងឡើងវិញទៀតហើយ។បើខ្មែរខ្វះសមត្ថភាពការពារទឹកដី ទឹកដីត្រូវតែរលាយ។ខ្មែរបាក់ស្បាតគ្រង់ខ្មែរមិនហ៊ាននិយាយការពិតឃើញបែបនេះទៅនិយាយបែបនោះឃើញបែបនោះទៅនិយាយបែបនេះ។បើដឹងថាខ្វះសមត្ថភាពហើយដើរចេញជាការប្រសើរយ៉ាងហោចណាស់ក៏យើងមានសម្ថភាពត្រង់យើងទទួលស្គាល់ខ្លួនយើងថាខ្វះសមត្ថភាព (au moins on est compétent de reconnaitre son incompétence) ប៉ុន្តែបុគ្គលខ្លះតាមអញ្ញាណរបស់ខ្លួនពុំបានដឹងថាខ្លួនខ្វះសមត្ថភាពទេ គេនៅតែញញឹមពព្រាយពេញចិត្តនឹងស្នាដៃរបស់គេ ទោះបីលទ្ធផលដែលបានមក គឺជាលទ្ធផលអវិជ្ជមានក៏ដោយ។

រួមសេចក្ដីមក សម្បត្តិវប្បធម៌ខ្មែរ ទោះបីជាសម្បត្តិវប្បធម៌លទ្ធកម្មក្ដី សម្បត្តិវប្បធម៌ធម្មជាតិក្ដី ក៏យើងជាខ្មែរត្រូវតែយល់តាមឲ្យបានច្បាស់លាស់ ព្រោះសម្បត្តិវប្បធម៌ទាំងនេះតំណាងព្រលឹងរបស់ខ្មែរ។ ចំណែកសម្បត្តិវប្បធម៌សំខាន់ជាងគេគឺមនុស្សខ្មែរ ព្រោះមនុស្សខ្មែរជាអ្នកការពារ បណ្ដុះបណ្ដាល និងធ្វើឱ្យលូតលាស់សម្បត្តិវប្បធម៌ដទៃទៀត។ហេតុនេះ យើងប្រឆាំងជាដាច់ខាតនឹងសង្គ្រាមសព្វយ៉ាង ពីសំណាក់បរទេសក្ដី ពីសំណាក់ជនជាតិឯងក្ដី ដែលបណ្ដាលឱ្យវិនាសដល់ពូជសាសន៍ខ្មែរ សូម្បីតែម្នាក់៕

---

## ១- ការពិនិត្យចុងក្រោយលើលិខិតបទដ្ឋានគតិយុត្ត

នៅថ្ងៃទី២២ ខែមករា ថ្ងៃទី១៨ ខែមិនា ថ្ងៃទី១២ ខែមិថុនា និងថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ ទីស្ដីការគណៈមន្ត្រីបានរៀបចំកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយលើការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនិងពិធីសារដូចមានរាយឈ្មោះខាងក្រោម តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រោមអធិបតីភាពឯកឧត្តម **តឺករ៉េត សំរេច** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការនៃទីស្ដីការគណៈរដ្ឋមន្ត្រី៖

-ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្ដីពីការទទួលស្គាល់ទៅវិញទៅមកការផ្ដល់អាជ្ញាបណ្ណបាហុនិកា(ក្រុមអាកាសយានិក)

-ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្ដីពីសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសសមាជិកអាស៊ានណាមួយ

-ការអនុម័តយល់ព្រមលើពិធីសារទី៤ ស្ដីពីការហោះហើរកូដំរមីណាល (Co-Terminal Rights) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ស្ដីពីសេវាកម្មដឹកជញ្ជូន តាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្ដីពីសេវាកម្ម

-ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១០នៃសេវាកម្មដឹក ជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្ដីពីសេវាកម្ម

ការប្រជុំពិនិត្យចុងក្រោយនេះបានអូសបន្លាយដោយសារការឆ្លងរាលដាលនៃជម្ងឺកូវិដ-១៩។ ជារួមអង្គប្រជុំបានឯកភាពទាំងស្រុងលើខ្លឹមសារនៃឯកសារទាំងអស់នេះប៉ុន្តែអង្គប្រជុំបានយកពេលវេលាយ៉ាងច្រើនដើម្បីពិភាក្សាលើអត្ថបទជាភាសាខ្មែរដែលបកប្រែចេញពីអត្ថបទភាសាអង់គ្លេស។ ជាធម្មតា ភាគីណាមួយនៃកិច្ចព្រមព្រៀងមិនអាចធ្វើវិសោធនកម្មដោយឯកតោភាគីលើឯកសារដែលបានចុះហត្ថលេខារួចហើយនោះទេ ប៉ុន្តែដោយភាគីនៃកិច្ចព្រមព្រៀងទាំងអស់មិនបានចុះហត្ថលេខាលើឯកសារជាភាសាជាតិរៀងៗខ្លួនហេតុនេះគេអាចធ្វើការកែប្រែបាន ពីព្រោះភាគីទាំងអស់បានឯកភាពយកអត្ថបទជាភាសាអង់គ្លេសជាគោល។

១/កិច្ចព្រមព្រៀងអាស៊ានស្ដីពីការទទួលស្គាល់ទៅវិញទៅមកការផ្ដល់អាជ្ញាបណ្ណបាហុនិកា(ក្រុមអាកាសយានិក)

១.១/ គោលបំណង:

កិច្ចព្រមព្រៀងអាស៊ានស្ដីពីការទទួលស្គាល់ទៅវិញទៅមកការផ្ដល់អាជ្ញាបណ្ណបាហុនិកា(ក្រុមអាកាសយានិក) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ នៅប្រទេសសឹង្ហបុរី ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ានលើកទី២៣ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម៖

-គាំទ្រចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥តាមរយៈការធ្វើសមាហរណកម្មយ៉ាងស៊ីជំរៅគ្រប់វិស័យ ជាពិសេសការកសាងឲ្យបានទីផ្សារអាកាសចរអាស៊ានតែមួយដែលមានលក្ខណៈប្រកួត ប្រជែង និងមានភាពរឹងមាំនៅក្នុងតំបន់អាស៊ាន

-ជួយសម្រួលនិងលើកកំពស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន

-កាត់បន្ថយរបាំងបច្ចេកទេសក្នុងវិស័យអាកាសចរដែលត្រួតគ្នានិងគ្មានប្រសិទ្ធភាព

-ធានាឲ្យបានសុវត្ថិភាព និសន្តិសុខអាកាសចរកម្រិតខ្ពស់បំផុត ដែលផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការធ្វើដំណើរតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន។

១.២/ សារប្រយោជន៍នៃកិច្ចព្រមព្រៀង

សម្រាប់ព្រះរាជាណាចក្រកម្ពុជា ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកការផ្តល់អាជ្ញាបណ្ណបាហុនិកា( ក្រុមអាកាសយានិក ) នឹងនាំមកនូវសារប្រយោជន៍ដូចខាងក្រោម៖

-បំពេញកាតព្វកិច្ចសមាជិកអាស៊ាន ដើម្បីសម្រេចនូវចក្ខុវិស័យនៃសហគមន៍សេដ្ឋ កិច្ចអាស៊ានឆ្នាំ២០២៥តាមរយៈការធ្វើសមាហរណកម្មស៊ីជម្រៅគ្រប់វិស័យជាពិសេសការកសាងឲ្យបានទីផ្សារអាកាសចរតែមួយ

-ជំរុញឲ្យកាន់តែល្អប្រសើរលើសកម្មភាពការងារសមាហរណកម្ម នៃវិស័យដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន

-កាត់បន្ថយរបាំងបច្ចេកទេសនៃការទទួលស្គាល់ទៅវិញទៅមកលើការអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណបាហុនិកា ជាមួយបណ្តាប្រទេសសមាជិកអាស៊ាន

-ធានាឲ្យបានសុវត្ថិភាពនិងសន្តិសុខអាកាសចរក្នុងកម្រិតខ្ពស់បំផុត ដែលអាចផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការធ្វើដំណើរតាមផ្លូវអាកាស។

២/ ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីសហការលើជើងហោះហើរក្នុងស្រុក ក្នុងរង្វង់ទឹកដីនៃប្រទេសសមាជិកអាស៊ានណាមួយ

៣/ការអនុម័តយល់ព្រមលើពិធីសារទី៤ស្តីពីការហោះហើរកូធ័រមីណាល ( Co-Terminal Rights ) រវាងអាកាសយានដ្ឋាននៅក្នុងទឹកដីនៃប្រទេសជាសមាជិកអាស៊ាន

សារប្រយោជន៍នៃពិធីសារទី៣និងទី៤

ចំពោះព្រះរាជាណាចក្រកម្ពុជា ការផ្តល់សច្ចាប័នលើពិធីសារទាំងពីរនេះ នឹងនាំមកនូវ សារប្រយោជន៍ដូចខាងក្រោម៖

-បំពេញកាតព្វកិច្ចសមាជិកអាស៊ាន ដើម្បីសម្រេចនូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០២៥ តាមរយៈការធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅគ្រប់វិស័យ ជាពិសេសការកសាងឲ្យបានទីផ្សារអាកាសចរអាស៊ានតែមួយ

-ជំរុញឲ្យកាន់តែល្អប្រសើរនូវសកម្មភាពការងារសមាហរណកម្មវិស័យដឹកជញ្ជូនតាមផ្លូវអាកាស នៅក្នុងតំបន់អាស៊ាន

-ផ្តល់ភាពងាយស្រួលដល់អ្នកធ្វើដំណើរតាមផ្លូវអាកាសជាជនជាតិខ្មែរ នៅក្នុងតំបន់អាស៊ាន

-ពង្រឹងនិងពង្រីកកិច្ចសហការលើជើងហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជា ជាមួយក្រុមហ៊ុនអាកាសចរណ៍នៅក្នុងតំបន់អាស៊ាន ជាលក្ខណៈសហការលើជើងហោះហើរក្នុងស្រុក និងជើងហោះហើរកូធ័រមីណាល ( Co-Terminal Rights )។

៤/ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩ស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម

៥/ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១០នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខណ្ឌអាស៊ានស្តីពីសេវាកម្ម

សារប្រយោជន៍នៃពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី៩និងទី១០

ការផ្តល់ការអនុម័តលើពិធីសារទាំងពីរនេះ ព្រះរាជាណាចក្រកម្ពុជានឹងទទួលបាននូវ សារប្រយោជន៍ដូចតទៅ៖

-បំពេញកាតព្វកិច្ចសមាជិកអាស៊ានដើម្បីសម្រេចនូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ ២០២៥ តាមរយៈការធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅគ្រប់វិស័យ ជាពិសេសការកសាងឲ្យបានទីផ្សារអាកាសចរអាស៊ានតែមួយ

-ជំរុញឲ្យកាន់តែល្អប្រសើរនូវសកម្មភាពការងារសមាហរណកម្មវិស័យដឹកជញ្ជូនតាមផ្លូវអាកាសនៅក្នុងតំបន់អាស៊ាន

-បង្កើនសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវាកម្ម និងផ្តល់ភាពទាក់ទាញបន្ថែមទៀត ដល់ការវិនិយោគលើផ្នែកសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

-នាំមកនូវការរីកចម្រើនដ៏រឹងមាំមួយនិងជាចលករយ៉ាងសំខាន់សម្រាប់នាំមកនូវភាពរីកចម្រើននៃវិស័យអាកាសចរស៊ីវិល និងសេដ្ឋកិច្ចប្រកបដោយចីរភាព។

ក្រៅពីសារប្រយោជន៍ដែលបានរៀបរាប់ខាងលើ កម្ពុជាក៏អាចជួបការលំបាកក្នុងការប្រកួតប្រជែងជាមួយនឹងសមាជិកអាស៊ានដទៃទៀត ពីព្រោះលទ្ធភាពនិងសមត្ថភាពរបស់កម្ពុជានៅមានកម្រិតនៅឡើយ។

កិច្ចព្រមព្រៀងនិងពិធីសារខាងលើនេះ ត្រូវបានដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីសម្រេចកាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០៕

*ដោយ ហែម ហេង - (ក.ស.វ. - ក្រុម ១)*

## ២- សេចក្តីព្រាងច្បាប់ស្តីពី

# ការគ្រប់គ្រងល្បែងពាណិជ្ជកម្ម

សេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១១ខែធ្នូឆ្នាំ២០១៧និងត្រូវបានឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនិងកិច្ចប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីមុននឹងត្រូវបានអនុម័តដោយសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២០។ គួរកត់សម្គាល់ថា កិច្ចប្រជុំជំនាញបច្ចេកទេសឆ្លងសេចក្តីព្រាងច្បាប់នេះមានចំនួនកិច្ចប្រជុំច្រើនជាងចំនួនកិច្ចប្រជុំជំនាញបច្ចេកទេសឆ្លងសេចក្តីព្រាងច្បាប់ផ្សេងទៀត៖ ចំនួន ២៤ពេល ក្នុងរយៈពេលជាងពីរខែ។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ រួមគ្នាសិក្សាយ៉ាងល្អិតល្អន់លើបទពិសោធន៍ និងឧត្តមានុវត្តនៃបណ្តាប្រទេសជឿនលឿនមួយចំនួនទាំងក្នុងនិងក្រៅតំបន់ ដូចជា ទីក្រុងឡាសវេហ្គាសបៃរដ្ឋនេវ៉ាដា សហរដ្ឋអាមេរិក ទីក្រុងមែលប៊ឺនប្រទេសអូស្ត្រាលី ទីក្រុងម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន ប្រទេសម៉ាឡេស៊ី ហ្វីលីពិន សិង្ហបុរី អង់គ្លេស បារាំង ម៉ាល់តា ...

យោងសេចក្តីថ្លែងហេតុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ល្បែងពាណិជ្ជកម្មត្រូវបានរាជរដ្ឋាភិបាលមើលឃើញថា បានប្រែក្លាយទៅជាឧបករណ៍កម្សាន្តនិងទាក់ទាញទេសចរនៅទូទាំងពិភពលោក... ប្រៀបដូចផលិតផលនៃវិស័យផលិតកម្មដទៃទៀតដែរវិស័យទេសចរណ៍កាន់តែរងសម្ពាធនៃការប្រកួតប្រជែងដ៏ខ្លាំងដែលទាមទារឱ្យមានការផ្នែប្រឌិតបន្ថែមពីលើសេដ្ឋកិច្ចសក្តានុពលនៃធម្មជាតិ។ ជាពិសេស ទីតាំងមណ្ឌលល្បែងពាណិជ្ជកម្មដែលរួមបញ្ចូលទាំងទីតាំងបដិសណ្ឋារកិច្ច ភោជនីយដ្ឋាន ផ្សារទំនើប សណ្ឋាគារ មណ្ឌលកីឡាមណ្ឌលកម្សាន្តនិងទស្សនាមណ្ឌលសន្និបាត ឬពិពណ៌ហាងលក់ទំនិញរួចពន្ធ។ល។និង។ល។ ត្រូវបានទទួលស្គាល់ជាទូទៅនៅលើពិភពលោកថាជាប្រភពចំណូលថវិកាដ៏សំខាន់និងជាទីតាំងការងារជាច្រើនប្រភេទនៃឧស្សាហកម្មគ្មានផ្សែង ដែលរួមចំណែកបង្កើតកំណើនសេដ្ឋកិច្ច។ អាស្រ័យហេតុនេះ បញ្ញត្តិកម្មនៃវិស័យល្បែងពាណិជ្ជកម្មក៏ត្រូវបានពិចារណាបង្កើតឡើងដើម្បីជំរុញវិស័យនេះ បង្កើនទំនុកចិត្តរបស់វិនិយោគិនលើគោលនយោបាយប្រកបដោយតម្លាភាពរបស់រាជរដ្ឋាភិបាល និងធានានិរន្តភាពចំពោះមុខការប្រកួតប្រជែងពីក្នុងតំបន់និងក្រៅតំបន់។ក្នុងទិសដៅបង្កើតប្រភពចំណូលដោយធានាបាននូវសណ្តាប់ធ្នាប់សន្តិសុខសុវត្ថិភាពសង្គម គ្រប់គ្រងការប្រព្រឹត្តល្បែងពាណិជ្ជកម្មប្រកបដោយសុច្ចរិតភាពរួចផុតពីការកេងបន្លំ ការលាងសម្អាតប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម។

ខ្លឹមសារសំខាន់នៃសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្មមាន៖

-បង្កើតគណៈកម្មការល្បែងពាណិជ្ជកម្មកម្ពុជា ហៅកាត់ថា គលក ដែលមានសមាសភាព ១១រូប ដែលត្រូវតែងតាំងឡើងដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន គលក។ រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន គលក និងរដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃមួយរូប ជាអនុប្រធាន។ សមាជិក ៩រូបទៀត មានរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប រដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ១រូប រដ្ឋលេខាធិការនៃក្រសួងទេសចរណ៍ ១រូប រដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ១រូប រដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ ១រូប អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ១រូប អគ្គស្នងការជាតិនៃក្រសួងមហាផ្ទៃ ១រូប អគ្គលេខាធិការនៃ គលក ១រូប និងអគ្គលេខាធិការរងនៃគលក ១រូប។

-គលក មានសិទ្ធិផ្តល់អាជ្ញាបណ្ណ័ អនុម័តប្រភេទល្បែង ចេញសេចក្តីណែនាំដល់ប្រតិបត្តិករល្បែងពាណិជ្ជកម្ម ចេញលិខិតបទដ្ឋានគតិយុត្តិសម្រាប់អនុវត្តក្នុងវិស័យនេះ និងសិទ្ធិអំណាចមួយចំនួនទៀត

-តំបន់ល្បែងពាណិជ្ជកម្មអាចដំណើរការក្នុងតំបន់អនុញ្ញាត្តិនិងមិនអាចដំណើរការក្នុងតំបន់ហាមឃាត់។

-គលក មានសិទ្ធិសម្រេចយល់ព្រម ឬបដិសេធលើពាក្យស្នើសុំអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែដោយពិចារណាលើធនធានហិរញ្ញវត្ថុសមត្ថភាពធុរកិច្ចបទពិសោធន៍ទ្រទ្រង់ស្ថាបត្យកម្មនៃគម្រោងប្លង់ស្ថាបត្យកម្ម

-ក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែ (រួមបញ្ចូលទាំងទីតាំងបដិសណ្ឋារកិច្ច ភោជនីយដ្ឋានផ្សារទំនើប សណ្ឋារគារ មណ្ឌលកីឡា មណ្ឌលកម្សាន្តនិងទស្សនា មណ្ឌលសន្និបាត ឬពីពណ៌ហាងលក់ទំនិញរូបពន្ធ។ល។) ប្រតិបត្តិករនិងកម្មសិទ្ធិករកាស៊ីណូត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងក្នុងអត្រា៤%សម្រាប់ភ្ញៀវល្បែងពិសេស និង ៧% សម្រាប់ភ្ញៀវល្បែងធម្មតា នៃចំណូលសរុបពីល្បែងពាណិជ្ជកម្ម ។

-ក្រៅមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែ ប្រតិបត្តិករ និងកម្មសិទ្ធិករកាស៊ីណូត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងក្នុងអត្រា ៧% នៃចំណូលសរុបពីល្បែងពាណិជ្ជកម្ម។

-ចំណូលសរុបពីល្បែងពាណិជ្ជកម្មត្រូវបានគណនាដោយយកចំណូលដែលទទួលបាន ឬត្រូវទទួលបានពីល្បែងពាណិជ្ជកម្មគ្រប់ប្រភេទដកចេញប្រាក់ឈ្នះទាំងអស់របស់ភ្ញៀវល្បែងពាណិជ្ជកម្ម។

-ល្បែងអនឡាញ មិនត្រូវបានអនុញ្ញាតឱ្យដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

ក្នុងអំឡុងពេលតាក់តែង និងកែសម្រួលដែលមានក្រសួងពាក់ព័ន្ធជាច្រើនបានចូលរួមក្នុងរយៈពេលជាងបីឆ្នាំកន្លងមក មានដំណើរការត្រៀមសម្រាប់ការអភិវឌ្ឍមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណែជាបណ្តើរៗ ដែលនាំឱ្យមានការកើនឡើងជីវភាពប្រជាជន ដោយការបង្កើតការងារថ្មី និងចំណូលពីវិស័យអចលនទ្រព្យពិសេសនៅតំបន់កំពង់សោម បាវិត ប៉ោយប៉ែត ...៕

*ដោយ អ៊ុច ថោងសេង - (ក.ស.វ. - ក្រុម ២)*

## គំនិតគួរពិចារណា

" ពេលវេលាជាមាសប្រាក់ ចំណេះល្បឿនគឺជាជីវិត "

គតិបណ្ឌិតប្រជាប្រិយ

## ៣- សេចក្តីព្រាងច្បាប់ស្តីពី

# ការអនុម័តយល់ព្រមលើវិសោធនកម្មទីក្រុងគីហ្គាលី នៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូន និងពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូននៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០១ និងបានផ្តល់សច្ចាប័នលើវិសោធនកម្មចំនួន៤ នៃពិធីសារម៉ុងរ៉េអាល់ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ រួមមាន វិសោធនកម្មទីក្រុងឡុងដ៍(ចក្រភពអង់គ្លេស) វិសោធនកម្មទីក្រុងកូប៉ិនហាហ្គេន(ប្រទេសដាណឺម៉ាក) វិសោធនកម្មទីក្រុងម៉ុងរ៉េអាល់(ប្រទេសកាណាដា) និងវិសោធនកម្មទីក្រុងប៉េកាំង(សាធារណរដ្ឋប្រជាមានិតចិន)។

ក្នុងនាមជាសមាជិកព្រះរាជាណាចក្រកម្ពុជាមានកាតព្វកិច្ចអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងវីយែន និងពិធីសារម៉ុងរ៉េអាល់ តាមវិធានការសមស្រប សំដៅការពារសុខភាពមនុស្សនិងការពារបរិស្ថានប្រឆាំងផលប៉ះពាល់ផ្សេងៗបណ្តាលមកពីសកម្មភាពមនុស្សដែលបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុបំផ្លាញស្រទាប់អូហ្សូនក្នុងកម្រិតមួយដែលមានឥទ្ធិពលអាក្រក់បង្កឲ្យមានការផ្លាស់ប្តូរ ឬមាននិន្នាការផ្លាស់ប្តូរស្រទាប់អូហ្សូន។

ដើម្បីការអនុវត្តអនុសញ្ញានិងពិធីសារឲ្យកាន់តែមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយនិងឈានទៅលុបបំបាត់ការផលិតនិងការប្រើប្រាស់សារធាតុបំផ្លាញអូហ្សូននិងសារធាតុហាយដ្រូហ្វ្លុយអរ៉ូកាបូន(Hydio-fiuoncanlion HFC3) ដែលជាសារធាតុបង្កឱ្យមានការកើនកម្តៅភពផែនដីខ្ពស់ (ប្រតិភូមកពីប្រទេសចំនួន ១៩៧ រួមទាំងកម្ពុជា និងតំណាងអង្គការអន្តរជាតិពាក់ព័ន្ធបានអនុម័តឆ្នាំ២០១៦ លើវិសោធនកម្មទីក្រុងគីហ្គាលី(ប្រទេសរវ៉ាន់ដា) នៃពិធីសារម៉ុងរ៉េអាល់។

វិសោធនកម្មទីក្រុងគីហ្គាលីបានចូលជាធរមានថ្ងៃទី១ខែមករាឆ្នាំ២០១៩និងបានដាក់ចេញនូវវិធានការចំពោះប្រទេសដែលមិនទាន់ផ្តល់សច្ចាប័នចូលជាសមាជិកនៃវិសោធនកម្មនេះ ក្នុងការត្រួតពិនិត្យចំពោះការផលិតនិងការប្រើប្រាស់សារធាតុ HFC3 (ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃវិសោធនកម្ម) និងការធ្វើពាណិជ្ជកម្មសារធាតុទាំងនេះ។ ដូច្នេះ ក្នុងស្ថានភាពដែលយើងមិនទាន់បានផ្តល់សច្ចាប័ននោះ យើងមិនអាចនាំចូលសារធាតុទាំងនេះមកប្រើប្រាស់បានឡើយ។

ក្នុងនាមជាសមាជិកនៃអនុសញ្ញា ពិធីសារ និងវិសោធនកម្មទីក្រុងគីហ្គាលី កម្ពុជាមានកាតព្វកិច្ចចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការទប់ស្កាត់នូវការបំផ្លាញស្រទាប់អូហ្សូន និងការកើនកម្តៅភពផែនដី តាមរយៈការរៀបចំប្រព័ន្ធស្នើសុំលិខិតអនុញ្ញាតកូតាក្នុងការផលិត ការនាំចេញ ការនាំចូល ការកាត់បន្ថយការប្រើប្រាស់សារធាតុ HFC3 និងឧបករណ៍ប្រើប្រាស់សារធាតុនេះ ជាពិសេសទូទឹកកក និងបរិក្ខារត្រជាក់មួយចំនួនដែលភាគច្រើនជាបរិក្ខារចាស់ៗ។

ការផ្តល់សច្ចាប័នទីក្រុងគីហ្គាលី មានសារប្រយោជន៍ដូចខាងក្រោម៖

១-ផ្នែកនយោបាយៈលើកកម្ពស់កិត្យានុភាពជាតិតាមរយៈការចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងកិច្ចប្រជុំពិភាក្សាដោះស្រាយបញ្ហារួមទាក់ទងនឹងសារធាតុបំផ្លាញស្រទាប់អូហ្សូន។

២-ផ្នែកបរិស្ថាន : ចូលរួមកាត់បន្ថយការកើនកម្តៅភពផែនដី ដែលបង្កឱ្យខូចខាតបរិស្ថានធម្មជាតិ ជីវៈចម្រុះ និងផលប៉ះពាល់ដល់សុខភាពសាធារណៈ។

៣-ផ្នែកបច្ចេកទេស : ទទួលបានគាំទ្របច្ចេកទេសក្នុងការបណ្តុះបណ្តាល ការទទួលនូវបច្ចេកវិទ្យាថ្មីៗ ការទទួលបាននូវព័ត៌មាននិងជំនួយថវិកាសម្រាប់អនុវត្តគម្រោងទាក់ទងនឹងការអនុវត្តវិសោធនកម្មនេះដូចជា ការកែច្នៃ ការត្រួតពិនិត្យលើការនាំចូលបរិក្ខារប្រើប្រាស់សារធាតុ HFC3 ប្រកបដោយសុវត្ថិភាព ដើម្បីបន្តការងារដែលព្រះរាជាណាចក្រកម្ពុជាបានទទួលតាមរយៈការរៀបចំនិងការអនុវត្តកម្មវិធីជាតិស្តីពីការគ្រប់គ្រងសារធាតុធ្វើឲ្យត្រជាក់។

៤-ផ្នែកសេដ្ឋកិច្ច : ១-មានសិទ្ធិក្នុងការនាំចូលសារធាតុ HFC3 សម្រាប់បំពេញតម្រូវក្នុងប្រទេស។ ២-ទទួលបានថវិកាក្នុងការអនុវត្តគម្រោងលើកទឹកចិត្តក្នុងការផ្លាស់ប្តូរប្រព័ន្ធម៉ាស៊ីនត្រជាក់រថយន្ត ការប្រើប្រាស់ឡើងវិញ ការកែច្នៃសារធាតុដែលបំពេញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់ និងថវិកាក្នុងការរៀបចំប្រព័ន្ធផ្តល់ការយល់ព្រមតាមប្រព័ន្ធអេឡិចត្រូនិកដែលអាចទប់ស្កាត់ចរាចរណ៍សារធាតុខុសច្បាប់និង ៣-ទទួលបានគម្រោងវិនិយោគ ដើម្បីកែសម្រួលចង្វាក់ផលិតកម្មពីការប្រើប្រាស់សារធាតុ HFC3 ទៅប្រើប្រាស់សារធាតុមិនបំផ្លាញស្រទាប់អូហ្សូនវិញ។

សេចក្តីព្រាងនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនៅទីស្តីការគណៈរដ្ឋមន្ត្រីថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ដឹកនាំដោយ ឯកឧត្តម **ឆីយ រឿន** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការចូលរួមពី ឯកឧត្តម **នៅ ចោនន័រ** និង ឯកឧត្តម **ឆាយ ខុម** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ផ្នែកលើសារប្រយោជន៍នៃវិសោធនកម្មនេះ តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌គាំទ្រ និងស្នើជំរុញនីតិវិធីដើម្បីឱ្យសេចក្តីព្រាងច្បាប់ឆាប់ទទួលបានការផ្តល់សច្ចាប័ន៕

*ដោយ ឆយ អូន - (ក.ស.រ. - ក្រុម ៣)*

## <u>ពាក្យស្លោកខ្មែរ</u>

" ឃ្វាលនគរដោយពលរដ្ឋប្រុសស្រី រួមសាមគ្គីតាមរដ្ឋបុរសជាតិ "

# IV- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២០ *



របាយការណ៍វិភាគនេះ ជាលទ្ធផលនៃកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ.) លើស្ថានភាព សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ក្រោមអធិបតីភាព **ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ឆៃលី** ប្រធាន ក.ស.វ. ដែលសមាសភាពចូលរួមមាន គណៈប្រតិបត្តិ ក.ស.វ. **ឯកឧត្តម នរ៉ាណាឫទ្ធិ អានន្ទយ៉ាត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធាន ក.ស.វ. និងជាប្រធានក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ព្រមទាំងអនុប្រធាន សមាជិក សមាជិកា និងជំនួយការនៃក្រុមការងារវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ហើយការរៀបចំរបាយការណ៍នេះដោយពឹងផ្អែកលើមូលដ្ឋានព័ត៌មាន ទិន្នន័យ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ដែលជាធាតុចូលផ្សេងៗទៀតពីថ្នាក់ដឹកនាំ ទីប្រឹក្សាបច្ចេកទេស សមាជិក សមាជិកា នៃក.ស.វ. ក្រសួងស្ថាប័នពាក់ព័ន្ធ និងមន្ត្រីអគ្គលេខាធិការដ្ឋាន នៃក.ស.វ. តាមប្រព័ន្ធតេលេក្រាម។

## ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡បើប្រៀបធៀបក្នុងឆមាសទី១ដូចគ្នាឆ្នាំ២០២០និងឆ្នាំ២០១៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង២,៨% ដែលអាចចាត់ទុកថា ជាកម្រិតទាបបើធៀបនឹងការចែងក្នុងគោលនយោបាយ (៣% - ៥%)។

តារាង១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់តាមខែពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា[P] | សីហា[P] | កញ្ញា[P] | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២០ | ខែដូចគ្នាឆ្នាំ | ៣,៦% | ២,៧% | ២,៨% | ១,៩% | ២,៤% | ៣,២% | ៣,៣% | ៣,២% | ៣,៦% | | | | |
| ២០១៩ | ខែដូចគ្នាឆ្នាំ | ១,៥% | ២,០% | ២,២% | ២,១% | ២,០% | ១,៤% | ២,២% | ២,១% | ១,៧% | ១,៣% | ១,៨% | ៣,១% | ១,៩% |
| ២០១៨ | ខែដូចគ្នាឆ្នាំ | ២,០% | ២,៣% | ២,៣% | ២,៧% | ២,៩% | ២,៩% | ២,៣% | ២,៦% | ២,៦% | ៣,១% | ២,៥% | ១,៦% | ២,៥% |

P : តួលេខខែ កក្កដា សីហា កញ្ញា និងប្រចាំឆ្នាំ២០២០ ជាតួលេខព្យាករណ៍(តាមវិធីសាស្ត្រ Decomposition)

តារាង១.២. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (តាមក្រុមទំនិញ)

| ក្រុមទំនិញ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០២០ | សន្ទស្សន៍មធ្យម ឆមាសទី១ ឆ្នាំ២០១៩ | អត្រាអតិផរណា នៃក្រុមទំនិញ |
|---|---|---|---|
| ទំនិញប្រើប្រាស់ (២៥៩ មុខ) | ១៨១,២% | ១៧៦,៣% | ២,៨% |
| ម្ហូបអាហារ | ២២៦,៥% | ២១៧,០% | ៤,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ១៧៤,៤% | ១៧០,៥% | ២,៣% |
| សម្លៀកបំពាក់ និងស្បែកជើង | ១៥៤,២% | ១៥០,៦% | ២,៤% |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងទៀត | ១២៨,៤% | ១២៧,៤% | ០,៨% |
| គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ១៥៣,៧% | ១៥២,៦% | ០,៨% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ។ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្តីត្រូវការរបស់ខ្លួន។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

| | | | |
|---|---|---|---|
| សុខាភិបាល | ១៣៧,៣% | ១៣៧,១% | ០,២% |
| ការដឹកជញ្ជូន | ១០៨,៦% | ១១៣,៤% | –៤,២% |
| ក្នុងនោះ ប្រេងសាំង | ៧៥,៧% | ៨៧,៧% | –១៣,៦% |
| ទូរគមនាគមន៍ | ៦៦,៩% | ៦៧,៣% | –០,៦% |
| ការកម្សាន្ត និងវប្បធម៌ | ១១៩,៩% | ១១៨,៩% | ០,៩% |
| ការសិក្សា | ១៦៤,៥% | ១៥៩,៥% | ៣,១% |
| ភោជនីយដ្ឋាន | ២៩៦,២% | ២៨៣,៩% | ៤,៣% |
| ទំនិញ និងសេវាកម្មផ្សេងៗ | ១៥១,៦% | ១៤៦,១% | ៣,៨% |

កំណត់សម្គាល់ : គ្រាគោលគឺត្រីមាសទី៤ ឆ្នាំ២០០៦ = ១០០%

- ➢ មុខទំនិញដែលឡើងថ្លៃខ្ពស់មានត្រីស្រស់ ៩,១% និងផ្លែឈើ ៤,៨%

➡**អត្រាប្តូរប្រាក់** : ជារួមអត្រាប្តូរប្រាក់មានស្ថេរភាព។ ប្រាក់រៀលមានការធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារ ប្រាក់បាត និងប្រាក់ដុង។

| ប្រភេទ | ចុងឆមាសទី១/២០២០ | ចុងឆមាសទី១/២០១៩ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤ ០៩៣៛ | ៤ ០៦៦៛ | ០,៧% |
| **៛/១បាត** | ១៣៣៛ | ១៣២៛ | ០,៨% |
| **៛/១ដុង** | ០,១៧៧៛ | ០,១៧៤៛ | ១,៧% |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិក្នុងឆមាសទី១ ឆ្នាំ២០២០ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

➢ចំណូលអនុវត្តបានចំនួន ១១ ២២៤,៧ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន ២ ៨០៦,២ លានដុល្លារស្មើនឹង ៤៦,១% នៃផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ចំណូលចរន្តមានចំនួន ១១ ០៥៥,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិក មានចំនួន ២ ៧៦៤,០ លានដុល្លារ ស្មើនឹង ៤៦,៣% នៃផែនការ និងចំណូលមូលធនចំនួន ១៦៨,៩ ប៊ីលានរៀល។

➢បើធៀបនឹងឆមាសទី១ដូចគ្នា ចំណូលថវិកាជាតិ ថយចុះ២,២% ដែលក្នុងនោះចំណូលចរន្ត ថយចុះ ២,៩% ។

➢ ក្នុងចំណូលចរន្ត :ចំណូលសារពើពន្ធក្នុង៦ខែដើមឆ្នាំនេះអនុវត្តបានចំនួន ១១ ០៣៧,៣ ប៊ីលានរៀល គិតជាដុល្លារ អាមេរិកមានចំនួន ២ ៧៥៩,៣ លានដុល្លារ។ បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩ ចំណូលសារពើពន្ធ ថយចុះ២,៣% ដែលក្នុងនោះ ពន្ធនិងអាករគយ ថយចុះ១៤,៤% ប៉ុន្តែចំណូលពន្ធដារកើនឡើង ១៣,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ)។ ចំណែកតាមតួលេខរតនាគារជាតិចំណូលសារពើពន្ធមានចំនួន ៩ ៩៣៣,៨ ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន ២ ៤៨៣,៥ លានដុល្លារ ស្មើនឹង៤៧,១% នៃផែនការប្រចាំឆ្នាំ។

ក្រាហ្វ ២.១. សមាសធាតុចំណូលសារពើពន្ធ តាមឆមាស (២០១៤-២០២០)




## តារាង២.១. សមាសភាពនៃចំណូលចរន្ត

| មុខចំណូល | អនុវត្ត ផែនការ | %ធៀបនឹងឆ.១ ឆ្នាំ២០១៩ | មុខចំណូល | អនុវត្ត ផែនការ | %ធៀបនឹង ឆ.១ឆ្នាំ២០១៩ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ(រតនាគារ)** | ៤៧,១% | –២,៥% | **ចំណូលមិនមែនសារពើពន្ធ** | ៦៥,៥% | +៥៣,០% |
| ✓ពន្ធនិងអាករគយ**(អ.នាគយនិងរដ្ឋាករ)** | | –១៤,៤% | ✓កាស៊ីណូ | ៧០,០% | កើនកំហុត |
| | | | ✓អាជ្ញាបណ្ណក្នុងស្រុក | ៧៧,៩% | +១៨៩,៩% |
| -ពន្ធគយ (របបនាំចូល) | | –២០,១% | ✓កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | ៣៧,៣% | –៥៥,៤% |
| -អាករពិសេសលើរបបនាំចូល | | –២១,៧% | ✓នេសាទ | ២០,០% | –៥៩,១% |
| -អាករលើតម្លៃបន្ថែមរបបនាំចូល | | –៩,៦% | ✓ រុក្ខាប្រមាញ់ | ១៧,៩% | –៦៦,១% |
| -អាករនាំចេញ | | –៦៣,៨% | ✓សម្បទានដី | ៤៩,៥% | +៣៨,៥% |
| -អាករបន្ថែមលើផលិតផល តេលសិលា | | +៨,៤% | ✓អាកាសចរណ៍ស៊ីវិល | ៣៣,៧% | +៣៨,៥% |
| | | | ✓ ផលទុនទេសចរណ៍ | ១៦,១% | –៥៩,៥% |
| ✓ ចំណូលពន្ធដារ**(អ.នា ពន្ធដារ)** | ៤៩,០% | +១៣,០% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ៤១,៦% | –២៣,៦% |
| -ពន្ធលើប្រាក់បៀវត្ស | ៤៦,៦% | +១២,៩% | ✓ ជួលសហគ្រាស សម្ភារៈ | ៤១,១% | +២,៧% |
| - ពន្ធលើប្រាក់ចំណូល | ៩៩,៧% | +៨៦,១% | | | |
| - អាករលើតម្លៃបន្ថែម | ៣៦,៩% | +៣,៤% | | | |
| -អាករពិសេស | ៤៥,៩% | +៨,១% | | | |
| -ចំណូលផ្សេងៗ | ៦៦,៣% | +៤៤,០% | | | |
| -ថវិកាខេត្ត–រាជធានី | ៥៩,២% | +៦៩,០% | | | |

➢ចំណាយថវិកាជាតិក្នុងឆមាសទី១ឆ្នាំ២០២០ អនុវត្តបានចំនួន ១០ ០៣៨,៣ ប៊ីលានរៀល គិតជាដុល្លារអាមេរិកមានចំនួន ២ ៥០៩,៦ លានដុល្លារ ស្មើនឹង ៣២,៣% នៃផែនការប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តសម្រេចបានចំនួន ៧ ៩៤៩,៥ ប៊ីលានរៀល ស្មើនឹង ៤៤,១% នៃផែនការ និងចំណាយមូលធនមានចំនួន ២ ០៨៨,៨ ប៊ីលានរៀល។

➢បើប្រៀបធៀបឆមាសទី១ ដូចគ្នាឆ្នាំ២០១៩ ចំណាយថវិកាជាតិកើនឡើង៣៧,៧% ក្នុងនោះចំណាយចរន្តកើនឡើង២៣,៨% និងចំណាយមូលធន កើនឡើង១៤០,០% ។

➢ថវិកាជាតិនាឆមាសទី១ឆ្នាំ២០២០ មានអតិរេកចំនួន ១ ១៨៦,៤ ប៊ីលានរៀល ស្មើនឹង ២៩៦,៦ លានដុល្លារអាមេរិក។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុនាចុងឆមាសទី១ឆ្នាំ២០២០មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ M2 មានចំនួន ១២៤ ១១៤,៤ ប៊ីលានរៀល កើនឡើង ១២,៣% ធៀបនឹងឆមាសទី១ ឆ្នាំ ២០១៩។

ក្រាហ្វ៣.សមាសធាតុរូបិយវត្ថុ

ចុងឆមាសទី១ឆ្នាំ២០១៩




នាចុងឆមាសទី១ឆ្នាំ២០២០




➢ការកើនឡើងនៃ M2 នេះបណ្តាលមកពីកំណើននៃរូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ ២៨,០% ប្រាក់បញ្ញើចរន្ត ៣,៨% និងប្រាក់បញ្ញើផ្សេងទៀត ១២,៨%។

➢ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន ១៦,២% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៨% នៃរូបិយវត្ថុ$M_2$។

➢**ទុនបម្រុងជារូបិយបណ្ណបរទេសដុល** មានចំនួន ១៩ ៥០៦,៥ លានដុល្លារ មានការ កើនឡើង២១,៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។

➢**ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ** មានចំនួន ១១៤ ០៧៩,៥ ប៊ីលានរៀល កើនឡើង៤៥,៦% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។

➢**ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** (សម្រាប់ឆមាសទី១ឆ្នាំ២០២០ តួលេខមិនទាន់ទទួលបាន)។

➢ *អត្រាការប្រាក់ប្រចាំឆ្នាំ*

| ប្រភេទអត្រាការប្រាក់ | ចុងឆមាសទី១ ឆ្នាំ២០២០ | ចុងឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,០% | ៤,០% | ២៦,៤% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៣,៣% | ៣,៦% | -៧,៤% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ៩,៧% | ១០,៣% | -៥,៩% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៨,០% | ៨,៦% | -៦,១% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៨% | ១៨,០% | -១,៣% |
| កម្ចីជារៀលនៅហត្ថាកសិករ | ១៧,៨% | ១៧,៩៨% | -១,១% |
| កម្ចីជារៀលនៅប្រាសាក់ | ១៥,០% | ១៦,៩% | -១១,១% |

## ៤. ស្ថានភាពកសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងវប្បធម៌

ក្នុងឆមាសទី១ ឆ្នាំ២០២០ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម :

### ➡កសិកម្ម

➢តារាងខាងក្រោមបង្ហាញផ្ទៃដីដំណាំផ្សេងៗ ឆ្នាំ ២០១៨ ២០១៩ និង៦ខែដើមឆ្នាំ២០២០។

| *ប្រភេទដំណាំ* | *ឆមាសទី១ -២០២០* | ឆ្នាំ២០១៩ | ឆ្នាំ២០១៨ |
|---|---|---|---|
| ផ្ទៃដីដាំស្រូវវស្សា (ពាន់ហិកតា) | ១ ៥៧៥,០ | ២ ៧៣១,៣ | ២ ៧៣៩,៤ |
| ផ្ទៃដីដាំពោត (ពាន់ហិកតា) | ៩១,០ | ១៩២,៥ | ១៩៣,៨ |
| ផ្ទៃដីដាំដំឡូងឈើ (ពាន់ហិកតា) | ៤៧១,០ | ៦២៣,១ | ៦០៣,៣ |
| ផ្ទៃដីដាំដំឡូងជ្វា (ពាន់ហិកតា) | ១,៧ | ៣,៧ | ២,៨ |
| ផ្ទៃដីដាំបន្លែគ្រប់មុខ (ពាន់ហិកតា) | ២៨,៥ | ៣៤,៧ | ៣២,៣ |
| ផ្ទៃដីដាំសណ្តែកបាយ (ពាន់ហិកតា) | ១៤,៧ | ២៣,៦ | ២៨,៧ |
| ផ្ទៃដីដាំសណ្តែកដី (ពាន់ហិកតា) | ៤,២ | ៧,៩ | ១១,១ |
| ផ្ទៃដីដាំសណ្តែកសៀង (ពាន់ហិកតា) | ២,២ | ២៦,០ | ៤៣,៨ |
| ផ្ទៃដីដាំកៅស៊ូសរុប (ពាន់ហិកតា) | ៤០៤,៧ | ៤០៥,៧ | ៤៣៦,៧ |
| ក្នុងនោះ ផ្ទៃដីចៀរជ័រ | ២៥០,១ | ២៥០,៥ | ២០១,៩ |

➢ ផលិតផលនេសាទមានចំនួន ៣៥៧,៨ **ពាន់តោន** កើនឡើង ៥,៧% បើធៀបនឹងឆមាសទី១ដូចគ្នាឆ្នាំ២០១៩។

### ➡រ៉ែ និងថាមពល

➢ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៦ ១៨៤,២ GWh កើនឡើង១២,៥% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ ក្នុងនោះ:(ធៀបនឹងឆមាសទី១ឆ្នាំ២០១៩)

- វារីអគ្គិសនីមានចំនួន ១ ២៧៦,៧ GWh កើនឡើង៣៥,៣%
- អគ្គិសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន ២ ៤៧៥,៤ GWh កើនឡើង១២,៤%
- អគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន ៥៦៦,០ GWh ថយចុះ៣,៨%
- និងអគ្គីសនីនាំចូលពីប្រ ទេសជិតខាងដោយមានចំនួន ១ ៨៦៦,២ GWh កើនឡើង៦,០% ។

➢ផលិតកម្មស៊ីម៉ង់ត៍មានចំនួន ៤ ០៧៤,២ ពាន់តោនមានការកើនឡើង២,០% ធៀបនឹងឆមាសទី១ឆ្នាំ ២០១៩។

➡ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

➢ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ២ ២៣៣,៦ លានដុល្លារ ថយចុះ៤៧,៨% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។

➢ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម:

| ប្រភេទ | ចំនួន :ឆមាសទី១ ឆ្នាំ២០២០ | ចំនួន:ឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | ១៤៩ | ១៣៧ | +៨,៨ |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៨៦១ | ១ ៦៣០ | +១៤,២ |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | | ៣៩ | |
| ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | | ២៥ | |

➡សំណង់

➢សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៨ ៦០៤,៣ ពាន់ម² កើនឡើង២២,៧% បើធៀបនឹងឆមាសទី១ ឆ្នាំ ២០១៩។ ការអនុញ្ញាតនេះ ជាទឹកប្រាក់មានចំនួន ៣ ៨៤២,៧ លានដុល្លារ កើនឡើង១៣,២% បើធៀបនឹង៦ ខែដើមឆ្នាំ២០១៩។ ក្នុងនោះប្រភេទសំណង់សំខាន់ៗមាន :

| *ប្រភេទសំណង់* | ពាន់ម² :ឆមាសទី១ ឆ្នាំ២០២០ | ពាន់ម² :ឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| លំនៅឋាន | ៤ ២៩៨,៥ | ៣ ៧៣៥,២ | +១៥,១% |
| ឧស្សាហកម្ម | ១ ០៦៩,៨ | ១ ០២០,៤ | +៤,៨% |
| ពាណិជ្ជកម្ម | ២ ២២០,៦ | ១ ៧៣០,០ | +២៨,៤% |
| ទេសចរណ៍ | ៣២៧,២ | ៤៥៨,៨ | -២៨,៧% |
| ... | | | |
| អនុញ្ញាតសរុប | ៨ ៦០៤,៣ | ៧ ០១៥,១ | +២២,៧% |

➢ **ដូច្នេះ** ក្នុងការអនុញ្ញាតឆមាសទី១ឆ្នាំនេះ សំណង់ដែលពេញនិយមគឺលំនៅឋាន (៥០,០% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (២៥,៨% នៃផ្ទៃក្រឡាសរុប)។

➡សេវាកម្ម និងទេសចរណ៍

➢ការចុះបញ្ជី និងលុបចេញពីបញ្ជី :

| *ប្រភេទ* | *ចំនួន :ឆមាស១ ឆ្នាំ ២០២០* | *ចំនួន :ឆមាស១ ឆ្នាំ២០១៩* | បម្រែបម្រួល |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៦ ៧៤៨ | ៣ ១៥៦ | -៥៣,២% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១៨៣ | ៥២ | +២៥១,៩% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ៣ ៧០១ | ៥ ១៨៦ | -២៨,៦% |

## ➡ការងារ

| ប្រភេទ | ឆមាសទី១ ឆ្នាំ ២០២០ (នាក់) | ឆមាសទី១ ឆ្នាំ ២០១៩ (នាក់) | បម្រែបម្រួល |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ(ទីភ្នាក់ងារមុខរបរ និងការងារ) | ៨ ៤៩៩ | ៨ ៨០៨ | -៣,៥% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ១៣៦ ១៦៨ | ៩៣ ០៤៩ | +៤៦,៣% |
| អ្នកទទួលបានការងារធ្វើក្នុងប្រទេស | ១១៥ ៣៤៨ | ៦២ ៤០៣ | +៨៤,៨% |
| អ្នកទទួលបានការងារធ្វើក្រៅប្រទេស | ២០ ៨២០ | ៣០ ៦៤៦ | -៣២,១% |

## ➡វិនិយោគ

### ➢គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក. (ថ្មី និងពង្រីក)

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០២០ | ឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| **អនុញ្ញាតសរុប** (លានដុល្លារ) ក្នុងនោះ : | ២ ៦៥៤,៧ | ៥ ១៨១,២ | -៤៨,៨% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១០១,៥ | ៦១,៩ | +៦៤,១% |
| វិស័យឧស្សាហកម្ម | ៩០៥,៥ | ៩២០,៦ | -១,៦% |
| ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេស | ១២៧,៧ | ៤៤៣,២ | -៧១,២% |
| វិស័យទេសចរណ៍ | ៣៣៥,៤ | ៣ ៧៧៤,១ | -៩១,១% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ១ ៣១២,៣ | ៤២៤,៧ | +២០៩,០% |
| **គម្រោងថ្មី និងគម្រោងពង្រីក (ចំនួន)** | ១៥០ | ១៥៣ | -២,០% |
| **បង្កើតការងារ (ពាន់នាក់)** | ៩២,៣ | ១៦៧,៣ | -៤៤,៨% |

➡**ទំនិញឆ្លងកាត់តាមកំពង់ផែ** (សរុប២កំពង់ផែ)មានចំនួន ៥ ១៥៣,៦ ពាន់តោន កើនឡើង ១,៧% ធៀបនឹងឆមាសទី១ឆ្នាំ២០១៩។ ក្នុងនោះ :

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០២០ (ពាន់តោន) | ឆមាសទី១ឆ្នាំ២០១៩ (ពាន់តោន) | បម្រែបម្រួល |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១ ៧៩៦,៧ | ១ ៨៦៨,៩ | -៣,៩% |
| កំពង់ផែកំពង់សោម | ៣ ៣៥៦,៩ | ៣ ២០០,០ | +៤,៩% |

### ➢ការចុះបញ្ជី និងចរាចរណ៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០២០ | ឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី(ពាន់គ្រឿង) | ២១៨៤, | ២៨០០, | -២២,០% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី (ពាន់គ្រឿង) | ៥០៤, | ៥៣៨, | -៦,៣% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ១ ៦១៩ | ២ ១៧០ | -២៥,៤% |

## ➡ អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០២០(ពាន់នាក់) | ឆមាសទី១ ឆ្នាំ២០១៩(ពាន់នាក់) | បម្រែបម្រួល |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤៤,០ | ៩៥,២ | -៥៣,៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៤១,៥ | ៦៦៧,០ | -៦៣,៦% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ១ ៦៨៧,៦ | ៥ ២៧២,១ | -៦៨,០% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៣១១,២ | ១ ០០៥,១ | -៦៩,០% |
| អ្នកទេសចរអន្តរជាតិមកដល់កម្ពុជា | ១ ១៨២,៨ | ៣ ៣៣៨,៥ | -៦៤,៦% |
| ✓តាមផ្លូវអាកាស | ៦៨២,៩ | ២ ៣៥៣,៩ | -៧១,០% |
| ✓ តាមផ្លូវគោក និងទឹក | ៥០០,០ | ៩៨៤,៥ | -៤៩,២% |

➡ ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ឆមាសទី១ ឆ្នាំ២០២០ | ឆមាសទី១ ឆ្នាំ២០១៩ | បម្រែបម្រួល |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៩៤,៦ | ១១៧,១ | -១៩,២% |
| ក្នុងនោះទទួល | ១៦,៨ | ១៣,៩ | +២០,៤% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ២៧៤,៥ | ៥៥២,៨ | -៥០,៣% |
| ក្នុងនោះទទួល | ១៦៤,៩ | ៣១៥,៧ | -៤៧,៨% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៦ ៩០០,៧ | ៨ ៧៤៨,៨ | -២១,១% |
| ក្នុងនោះហៅចូល | ២ ៧៨៧,១ | ២ ៩៤៥,៣ | -៥,៤% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១៩ ៩៥៧,០ | ៣៧ ០៣១,០ | -៤៦,១% |
| ក្នុងនោះហៅចូល | ១៩ ៦៤៣,៦ | ៣៦ ៦៦៣,០ | -៤៦,៤% |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ:

➡ការនាំចូលក្នុងឆមាសទី១ ឆ្នាំ២០២០មានចំនួន ៣៦ ៦០១,១ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៩ ១៥០,៣ លានដុល្លារ ថយចុះ៤,២% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ក្នុងនោះមុខទំនិញគួរកត់សម្គាល់មាន:

| បរិយាយ | %Δ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៩ | បរិយាយ | %Δ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៩ |
|---|---|---|---|
| ប្រេងសាំង<br>ប្រេងម៉ាស៊ូត | +៦,៧%<br>+៨,៩% | ត្រាក់ទ័រនិងគោយន្ត(ជាគ្រឿង)<br>ម៉ូតូ(ជាគ្រឿង) | -៣១,៣% |
| ឧស្ម័ន | -៤,៨% | អង្ករ | -៥៥,៨% |
| ប្រេងខ្មៅ | +៨៥,១% | ផ្លែឈើនិងបន្លែ | +៧៥,២% |
| អគ្គិសនីនាំចូលដោយ EDC | +១៦,៦% | ជីកសិកម្ម | +១៩៨,៨% |
| ដែកសំណង់ | -៤៥,៣% | ថ្នាំកសិកម្ម | +៥៦,៥% |
| ស៊ីម៉ង់ត៍ | +៣,០% | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១១,២% |
| រថយន្តសរុប (ជា ព.ល.រ) | -២១,៧% | | |
| រថយន្តសរុប (ជាគ្រឿង) | -២៥,៦% | | |

➡**ការនាំចេញ** ក្នុងឆមាសទី១ ឆ្នាំ២០២០ មានចំនួន ៣១ ៤១៣,៥ ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៧ ៨៥៣,៤ លានដុល្លារ (មានចំនួន៨៥,៨%នៃការនាំចូល) មានការ កើនឡើង ១៥,៩% ធៀបនឹងឆមាសទី១ ឆ្នាំ២០១៩។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៩ | ទំនិញ | %Δ ធៀបនឹងឆ.ទី១ ឆ្នាំ២០១៩ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៤០,៧% | ផលិតផលនេសាទ | -២២,៦% |
| វាយនភណ្ឌនិងស្បែកជើង | -៨,៤% | កៅស៊ូ | -៨,៧% |
| អង្ករ | +៤០,១% | | |

## ១- បទពិសោធក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយឆ្លើយតបនឹងយេនឌ័រក្នុងវិស័យសេដ្ឋកិច្ចនៅកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាបានប្ដេជ្ញាចិត្តខ្ពស់ក្នុងការលើកម្ពស់សមភាពយេនឌ័រ ដោយបានបង្កើតនូវយន្តការ ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះព្រះរាជាណាចក្រកម្ពុជាទទួលបាននូវភាពរីកចម្រើនជាបន្តបន្ទាប់ទាក់ទងនឹងការងារលើកកម្ពស់សមភាពយេនឌ័រ ផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្រ្តបញ្ជ្រាបយេនឌ័រ គឺការផ្ដោតការយកចិត្តទុកដាក់លើការលើកកម្ពស់ ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ ការផ្ដល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីគឺជាយុទ្ធសាស្រ្តគន្លឹះមួយដើម្បីលើកកម្ពស់យេនឌ័រនិងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

រាជរដ្ឋាភិបាលបានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ព្រោះចំនួនស្ត្រីនៅកម្ពុជា មានច្រើនជាងពាក់កណ្ដាលនៃចំនួនប្រជាជនសរុប ហើយដែលជាតំណាងដល់ចំណែកមួយដ៏ធំនៃកម្លាំងពលកម្មនៅកម្ពុជា ដោយហេតុថា ចំនួនស្ត្រីដែលមានអាយុចាប់ពី១៥ឆ្នាំ សរុបមានចំនួនប្រមាណ ៨០,៤% កំពុងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច ព្រមទាំងបានរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យកំណើនសេដ្ឋកិច្ចជាតិបានឡើងខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ កំណើនខ្ពស់នៃសេដ្ឋកិច្ចជាតិនេះ បានផ្ដល់នូវផលប្រយោជន៍និងកាលានុវត្តភាពដល់ប្រជាពលរដ្ឋគ្រប់រូបទាំងស្ត្រីនិងបុរស។ភាពរីកចម្រើនរបស់ស្ត្រីនិងក្មេងស្រីក្នុងការទទួលបានសេវាអប់រំបានបង្កឱកាសឱ្យស្ត្រីមានលទ្ធភាពទទួលបានការងារសមរម្យមានប្រាក់ចំណូលខ្ពស់ និងចូលរួមគាំទ្រអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយភាពងាយរងគ្រោះរបស់ក្រុមគ្រួសារ ក៏ដូចជារួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសជាតិ។ក្នុងឆ្នាំ២០១៥ចំណែករបស់ស្ត្រីដែលបានចូលរួមក្នុងវិស័យកសិកម្មមាន ៤៩% វិស័យឧស្សាហកម្មមាន ៤៦.១% និងវិស័យសេវាកម្មមាន ៣៦% (អង្កេតសេដ្ឋកិច្ចនិងសង្គមកិច្ចកម្ពុជាឆ្នាំ២០១៥របស់វិទ្យាស្ថានជាតិស្ថិតិ)។ម្យ៉ាងទៀតចំនួនស្ត្រីជាសហគ្រិនមានការកើនឡើងគួរឱ្យកត់សម្គាល់ហើយសហគ្រិនស្ត្រីបានចូលរួមក្នុងវិស័យពាណិជ្ជកម្មនិងនាំចេញផលិតផលទៅកាន់ទីផ្សារអន្តរជាតិ។ ជាក់ស្ដែង ៦៥% នៃសហគ្រាសខ្នាតតូច និងមធ្យមដែលបានចុះបញ្ជី គឺដឹកនាំដោយស្ត្រី។

ការបង្កើតសមាគមសហគ្រិនស្ត្រីនៅកម្ពុជាបានផ្ដល់ជាវេទិកាសម្រាប់អ្នកជំនួញស្ត្រីអាចលើកឡើងអំពីបញ្ហាប្រឈមនានាជូនទៅរាជរដ្ឋាភិបាលបានដឹងនិងជួយរកដំណោះស្រាយជូនដល់សហគ្រិនស្ត្រី។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏ស្ត្រីជាសហគ្រិនក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធនិងសហគ្រាសខ្នាតមីក្រូទាំងនោះ នៅតែជួបនូវបញ្ហាប្រឈម និងឧបសគ្គជាច្រើននៅក្នុងការប្រតិបត្តិការធុរកិច្ចរបស់ខ្លួន ( World Economic Forum, The Global Gender get report 2020 )។

ដូច្នេះ ដើម្បីពង្រឹងភាពអង់អាចរបស់ពួកគេយើងត្រូវបន្តៈ

- កាត់បន្ថយនូវគម្លាតយេនឌ័រ
- ផ្ដល់ជំនាញបច្ចេកទេសនិងសហគ្រិនភាពដល់ស្ត្រី
- ផ្ដល់ឱកាសឲ្យស្ត្រីទទួលបាននូវការងារមានកម្រៃខ្ពស់ ដោយផ្ដល់ឱកាសនិងលើកទឹកចិត្តឱ្យស្ត្រីនិងក្មេងស្រីបានចូលរួមរៀនសូត្រនៅកម្រិតឧត្តមសិក្សាឱ្យបានច្រើន និងចាប់យកមុខជំនាញដែល

ទាក់ទងនឹងវិស័យដែលទីផ្សារក្នុងពិភពលោកកំពុងត្រូវការ គឺផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM- Science, Technology, engineering and mathematics) ដើម្បីងាយស្រួលក្នុងការរកការងារធ្វើនិងបានកម្រៃខ្ពស់។

- ផ្តល់នូវប្រភពឥណទានដែលមានការប្រាក់ទាប

ការងារទាំងអស់ខាងលើនេះ យើងក៏មិនអាចខ្វះបានពីការចូលរួមគាំទ្រពីសំណាក់បុរសផងដែរ ព្រោះថា បុរសមានចំនួនភាគច្រើនក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចគឺ អ្នកដឹកនាំ អ្នកទទួលបន្ទុកគ្រួសារ ប្រធានអង្គភាពសាធារណៈនិងឯកជន និយោជក ប្រធានអង្គការ សមាគម...។ ការចូលរួមគាំទ្រពីបុរស គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ក្នុងការជួយគាំទ្រនិងលើកកម្ពស់សមភាពយេនឌ័រ។

ទន្ទឹមនឹងនេះ ស្ត្រីក៏ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនដើម្បីបង្ហាញអំពីសមត្ថភាព តម្លៃនិងតួនាទីសំខាន់របស់ខ្លួនយើងក្នុងភាពជាអ្នកដឹកនាំ ដូចជាក្នុងការបំពេញការងារ ដោយត្រូវហ៊ានបង្កើតគោលបំណងច្បាស់លាស់មួយសម្រាប់អនាគតរបស់ខ្លួននិងកំណត់គោលដៅផ្សេងៗដែលនាំស្ត្រីឲ្យឈានទៅមុខ។ដើម្បី សម្រេចគោលបំណងនេះបាន ស្ត្រីត្រូវចេះប្រើប្រាស់នូវសមត្ថភាពសក្តានុពល និងគំនិតច្នៃប្រឌិតរបស់ខ្លួន។ ទាំងអស់ខាងលើនេះជាមូលហេតុធ្វើឲ្យសហគ្រិនស្ត្រីត្រូវបានគេមើលឃើញនិងឲ្យតម្លៃខ្ពស់។

ផ្អែកតាមការប៉ាន់ស្មានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រសិនបើកម្ពុជាយើងអាចបង្កើតបាននូវបរិយាកាសដែលគាំទ្រនិងអំណោយផលដល់ប្រព័ន្ធអេកូឡូស៊ីសហគ្រិន នោះ

(១)កម្ពុជាអាចនឹងទទួលបានចំណូលខ្ពស់ជាងមុនប្រមាណ ២៥ពាន់លានដុល្លារអាមេរិច (២៥ប៊ីលានដុល្លារ)

(២)បន្ថែមនៅក្នុងសេដ្ឋកិច្ចជាតិ ហើយកម្ពុជាអាចទទួលបានចំណូលបន្ថែមបានខ្ពស់ជាងមុន ប្រសិនបើកម្ពុជាអាចពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។ជាពិសេសសហគ្រិនភាពស្ត្រីត្រូវបានយកចិត្តទុកដាក់ខ្ពស់ដោយធានាបាននូវការកាត់បន្ថយភាពរងគ្រោះរបស់សហគ្រិនស្ត្រីនិងធ្វើយ៉ាងណាឲ្យស្ត្រីទទួលនូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ជំនាញនិងចំណេះដឹងកម្រិតខ្ពស់ ក៏ដូចជាព័ត៌មានថ្មីៗពីនិន្នាការធុរកិច្ចនាពេលបច្ចុប្បន្ន។

(៣)ឆ្នាំ២០១៩វេទិកាសេដ្ឋកិច្ចពិភពលោកបានបង្ហាញថា កម្ពុជាស្ថិតក្នុងលំដាប់ទី ១០៦ ក្នុងចំណោម ១៤១ប្រទេស ដែលមានភាពប្រសើរជាងមុនប្រៀបធៀបក្នុងឆ្នាំ២០១៨។

(៤)ដូច្នេះយើងទាំងអស់គ្នាត្រូវខិតខំពង្រឹងសមត្ថភាពជំនាញ ពង្រឹងផលិតភាព បង្កើតនវានុវត្តន៍និងមូលធនមនុស្សកម្រិតខ្ពស់ផងដែរដែលជាមូលហេតុចម្បងក្នុងការពង្រីកភាពប្រកួតប្រជែងរបស់យើងលើឆាកអន្តរជាតិ។កត្តាសំខាន់ យើងមិនត្រូវមើលរំលងអំពីសារៈសំខាន់នៃការចងបណ្តាញគ្នាដើម្បីចែករំលែក នូវបទពិសោធ ចំណេះដឹង ជំនាញ ព្រមទាំងរួមគ្នារិះរកនូវគំនិតច្នៃប្រឌិតនានាក្នុងការអភិវឌ្ឍធុរកិច្ចរបស់ខ្លួន ដើម្បីឈានឆ្ពោះទៅរកភាពប្រកួតប្រជែងរបស់យើងជាសកល។ ដើម្បីសម្រេចបាននូវអ្វីដែលបានលើកទាំងអស់ខាងលើនេះទាមទារនូវការចង្អុលបង្ហាញនិងណែនាំរបស់ក្រសួងកិច្ចការនារីនិងក្រុមប្រឹក្សាជាតិដើម្បីស្ត្រីដែលជាយន្តការជាតិ សម្រាប់លើកកម្ពស់សមភាពយេនឌ័រនិងបង្កើតភាពអង់អាចដល់ស្ត្រី ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការធានាឲ្យសម្រេចបាននូវគោលបំណងរបស់ស្ត្រីតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រនិងសកម្មភាពគន្លឹះជាច្រើន (ផែនការយុទ្ធសាស្ត្រនារីរតនៈ) ដោយផ្តល់ការគាំទ្រ ការប្រឹក្សាយោបល់ទាំងផ្នែកបច្ចេកទេស និង យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបយេនឌ័រដល់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។

ដោយ ខួត ទងផ្កា

# ២- កិច្ចប្រជុំលើកទី ៨ នៃយន្តការសន្ទនារវាងគណបក្សកាន់អំណាច ចិន និង រុស្ស៊ី

ប្រធានាធិបតីចិន X Jinping និងប្រធានាធិបតីរុស្ស៊ី Vladimir Putin នៅថ្ងៃព្រហស្បត៍នេះបានផ្ញើលិខិតអបអរសាទរដល់កិច្ចប្រជុំលើកទី៨ នៃយន្តការសន្ទនារវាងគណបក្សកាន់អំណាចចិននិងរុស្ស៊ី ដែលធ្វើឡើងតាមរយៈតំណភ្ជាប់វីដេអូ។

លោក Xi បាននិយាយថា ចាប់តាំងពីការផ្ទុះឡើង នៃ COVID-១៩ ចិននិងរុស្ស៊ីបានគាំទ្រ និងជួយគ្នាព្រមទាំងធ្វើការជាមួយគ្នាលើការលំបាកនិងប្រឆាំងការជ្រៀតជ្រែកពីខាងក្រៅផ្តល់នូវអត្ថន័យយុទ្ធសាស្ត្រថ្មីដល់កិច្ចសហប្រតិបត្តិការទ្វេភាគីបង្ហាញយ៉ាងពេញលេញនូវចំណងមិត្តភាពដ៏ជ្រាលជ្រៅរវាងប្រជាជននៃប្រទេសទាំងពីរ និងឆ្លុះបញ្ចាំងពីកម្រិតខ្ពស់និងភាពប្លែកនៃទំនាក់ទំនងចិន-រុស្ស៊ីក្នុងយុគសម័យថ្មី។

ដោយកត់សម្គាល់ថា ប្រទេសចិននិងរុស្ស៊ីគឺជាប្រទេសធំៗ ដែលមានការទទួលខុសត្រូវ និងជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ លោក Xi បាននិយាយថាប្រទេសទាំងពីរគួរតែបន្តពង្រឹងការប្រាស្រ័យទាក់ទង និងការសម្របសម្រួលជាយុទ្ធសាស្ត្រ និងចូលរួមវិភាគទានឱ្យបានកាន់តែ ច្រើនដើម្បីរួមគ្នាឆ្លើយតបទៅនឹងហានិភ័យនិងបញ្ហាប្រឈមនានាប្រឆាំងនឹងលទ្ធិនិយម និងសកម្មភាពឯកតោភាគី។ ថែរក្សាសន្តិភាព និងស្ថេរភាពពិភពលោកការពារយុត្តិធម៌ និងយុត្តិធម៌អន្តរជាតិ និងលើកកម្ពស់ការកសាងសហគមន៍មួយដែលមានអនាគតរួមគ្នាសម្រាប់មនុស្សជាតិ។

លោក Xi បានសង្កត់ធ្ងន់ថា យន្តការសន្ទនារវាងគណបក្សកាន់អំណាចចិននិងរុស្ស៊ីគឺជាវេទិកា និងបណ្តាញដ៏សំខាន់មួយសម្រាប់ការទំនាក់ទំនងនិងសម្របសម្រួលយុទ្ធសាស្ត្រ ទ្វេភាគី។

លោកបានសម្តែងក្តីសង្ឃឹមថាអ្នកតំណាងនៃគណបក្សទាំងពីរនឹងមានការផ្លាស់ប្តូរគ្នានិងការប្រាស្រ័យទាក់ទងគ្នាយ៉ាងស៊ីជម្រៅលើប្រធានបទនៃកិច្ចប្រជុំនេះនិងចូលរួមចំណែក ប្រាជ្ញានិងកម្លាំងរបស់ពួកគេដើម្បីធ្វើឱ្យស៊ីជម្រៅការសម្របសម្រួលយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងចិននិងរុស្ស៊ីនៅក្នុងយុគសម័យថ្មី។

លោក Putin បានថ្លែងនៅក្នុងសារអបអរសាទរ របស់លោកថា ទំនាក់ទំនងរុស្ស៊ី-ចិនបានឈានដល់កម្រិតមួយដែលមិនធ្លាប់មានពីមុនមកនិងធ្វើជាគំរូសម្រាប់ការសម្របសម្រួលរវាងប្រទេសនានា។ភាគីទាំងពីរបានខិតខំប្រឹងប្រែងរួមគ្នាដើម្បីដោះស្រាយបញ្ហាក្នុងតំបន់និងពិភពលោកព្រមទាំងរួមគ្នាលើកកម្ពស់និងការពារសន្តិសុខនិងស្ថេរភាពអន្តរជាតិ។

ដោយកត់សម្គាល់ថា ការសន្ទនារវាងគណបក្សកាន់អំណាចរុស្ស៊ីនិងចិន តែងតែជាផ្នែកមួយដ៏សំខាន់នៃទំនាក់ទំនងទ្វេភាគី លោក Putin បាននិយាយថា គណបក្សរួបរួមរុស្ស៊ីនិងគណបក្សកុម្មុយនិស្តចិនបានផ្លាស់ប្តូរបទពិសោធន៍គ្នាជាទៀងទាត់លើកកម្ពស់គម្រោងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកទ្វេភាគីនៅក្នុងវិស័យផ្សេងៗគ្នានិងដោយជះឥទ្ធិពលពីផលប៉ះពាល់នៃ COVID-19 ពួកគេបានបន្តជំរុញកិច្ចសហប្រតិបត្តិការដែលពាក់ព័ន្ធតាមរយៈទម្រង់ថ្មីនៃការទំនាក់ទំនងពីចម្ងាយ។

លោក Putin បានបង្ហាញជំនឿថា កិច្ចប្រជុំនេះនឹងមានការពិភាក្សាដ៏សំបូរបែប និងមានប្រយោជន៍ដាក់ចេញនូវគំនិតនិងគំនិតផ្តួចផ្តើមថ្មីៗនិងពង្រឹងបន្ថែមទៀតនូវភាពជាដៃគូយុទ្ធសាស្ត្រនៃការសម្របសម្រួលគ្នារវាងរុស្ស៊ីនិងចិន៕

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

## សកម្មភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែមិថុនាឆ្នាំ២០២០ |
|---|---|---|
| ១ | ០២/៦/២០<br>ម៉ោង១៥:០០នាទី | ដឹកនាំគណៈប្រតិភូនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខ័ន្ធ សពឯកឧត្តម **សូម ជីវគុណា** សមាជិក ក.ស.វ. នៅវត្តស្លាកែត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល។ |
| ២ | ០៥/៦/២០<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមេសា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៨/៦/២០<br>ម៉ោង១៥:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឱន ឌីរៈ** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៩/៦/២០<br>ម៉ោង១០:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឆយ អូន** អនុប្រធាន ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៩/៦/២០<br>ម៉ោង១៦:០០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឈឿង ស៊ីម៉ូណា** និងឯកឧត្តម **ម៉ម សារិទ្ធ** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៧/៦/២០<br>ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **នរ៉ាណាឫទ្ធិ អានន្ទយ៉ាត** អនុប្រធាន ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | ២២/៦/២០<br>ម៉ោង០៩:៣០នាទី | ជួបពិភាក្សាការងារជាមួយឯកឧត្តម **លី គឹមសុខ** និងឯកឧត្តម **អ៊ុំ ឌុខ** អនុប្រធាន ក.ស.វ. និងឯកឧត្តម **រ័ត្ន សណ្ដាប់** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ២៤/៦/២០<br>ម៉ោង០៩:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ "កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៩ | ២៩/៦/២០<br>ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមិថុនា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ៣០/៦/២០<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្ដីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែឧសភា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែកក្កដាឆ្នាំ២០២០ |
|---|---|---|
| ១ | ០១/៧/២០<br>ម៉ោង០៩:០០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។<br>២- សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។ |

| | | |
|---|---|---|
| | | ៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | **០២/៧/២០<br>ម៉ោង០៩:៣០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **០៣/៧/២០<br>ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៤ | **០៩/៧/២០<br>ម៉ោង០៨:១៥នាទី** | ចូលរួមជាកិត្តិយស ក្នុងកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអនុវត្តអនុសញ្ញាការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) ផ្សាភ្ជាប់ច្បាប់ជាតិពាក់ព័ន្ធ និងអនុសាសន៍របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | **១៣/៧/២០<br>ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ឡាយ ឬទ្ធី** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

| | | |
|---|---|---|
| ៦ | **១៥/៧/២០ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ហង្ស មឿន** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៧ | **១៦/៧/២០ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ហែម សាឯម** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | **១៧/៧/២០ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **ញឹក គោសល្យវិឌ្ឍ** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធានក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | **២១/៧/២០ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីច្រូតស្រូវជាមួយបងប្អូនប្រជាកសិករនៅភូមិសេដ្ឋី និងភូមិពន្ទង ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិពន្ទង ឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ។ |
| ១០ | **២៤/៧/២០ ម៉ោង០៩:៣០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ុច ថុន** សហប្រធាន និងឯកឧត្តម **ម៉ិច សុខា** សហប្រធានស្តីទី នៃក្រុមការងារចុះមូលដ្ឋានឃុំក្តាញ់ នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **២៩/៧/២០ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | **៣០/៧/២០ ម៉ោង១៦:០០នាទី** | ជួបពិភាក្សាការងារជាមួយឯកឧត្តម **សៅ ខូសាន្ត** សមាជិក ក.ស.វ. នៅការិយាល័យឯកឧត្តមប្រធាន ក.ស.វ. នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាពក្នុងខែសីហាឆ្នាំ២០២០ |
|---|---|---|
| ១ | **០៤/៨/២០ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំឆមាសទី១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | **១២/៨/២០ ម៉ោង០៩:០០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីជំឡងមី ២០២០-២០២៥។<br>២- សេចក្តីព្រាងរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ក្នុងឆ្នាំ២០១៧-២០១៨។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីនីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.២- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រុងគីហ្គាលី នៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន<br>៣.៣- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា ស្តីពីបារត |

| | | |
|---|---|---|
| | | ៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង<br>៣.៥-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | **១៣/៨/២០<br>ម៉ោង០៩:៣០នាទី** | ចូលរួមជាសមាជិកក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងពិភាក្សាលើ៖<br>១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥។<br>២- សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥(IDP)ក្នុងឆ្នាំ២០១៧-២០១៨។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីនីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.២- សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រុងគីហ្កាលី នៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន<br>៣.៣- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា ស្តីពីបារត<br>៣.៤- សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង<br>៣.៥-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | **១៣/៨/២០<br>ម៉ោង១៥:០០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំព្រៃល្វា ស្រុកព្រៃកប្បាស នៅការិយាល័យឯកឧត្តមប្រធាន ក.ស.រ.នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | **១៤/៨/២០<br>ម៉ោង០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១- សេចក្តីព្រាងគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥។<br>២- សេចក្តីព្រាងរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិ-វឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ក្នុងឆ្នាំ២០១៧-២០១៨។ |

| | | |
|---|---|---|
| | | ៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីនីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.២- សេចក្ដីព្រាងច្បាប់ ស្ដីពីវិសោធនកម្មក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន<br>៣.៣- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា ស្ដីពីបារត<br>៣.៤- សេចក្ដីព្រាងច្បាប់ស្ដីពីការអនុម័តយល់ព្រមលើអនុសញ្ញា ស្ដីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង<br>៣.៥-សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។<br>នៅទីស្ដីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៦ | **២៥/៨/២០**<br>**ម៉ោង១៥:៤៥នាទី** | ទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ី សារី** ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានឃុំព្រៃល្វា នៃស្រុកព្រៃកប្បាស នៅការិយាល័យឯកឧត្តមប្រធាន ក.ស.រ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៧ | **២៧/៨/២០**<br>**ម៉ោង០៩:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ទទួលផែនទីឋានលេខាព្រំដែនគោកកម្ពុជា-វៀតណាម ខ្នាត ១/២៥០០០ ក្រោមអធិបតីភាព សម្ដេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាតំណាងដ៏ខ្ពង់ខ្ពស់បំផុត សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីស្ដីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៨ | **៣១/៨/២០**<br>**ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំគណៈប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែសីហា នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

| **ល.រ** | **កាលបរិច្ឆេទ** | **សកម្មភាពក្នុងខែកញ្ញាឆ្នាំ២០២០** |
|---|---|---|
| ១ | **០១/៩/២០**<br>**ម៉ោង០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឆយ អូន** ឯកឧត្តម **សួន លាងហៃ** និងឯកឧត្តម **សំ សំណាង** នៅការិយាល័យឯកឧត្តមប្រធាន ក.ស.រ. នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | **០២/៩/២០**<br>**ម៉ោង០៩:០០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១- សេចក្ដីព្រាងច្បាប់ស្ដីពីមូលបត្ររដ្ឋ។<br>២- សេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំនិ ងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖ |

| | | |
|---|---|---|
| | | ៣.១- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា<br>៣.២- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីវិនិយោគរវាងបណ្ដារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.៣- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីមួយវិសោធនកម្មកិច្ចព្រមព្រៀង ស្ដីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន<br>៣.៤- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម<br>៣.៥- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្ដីពីការទទួលស្គាល់ទៅវិញទៅមកការផ្ដល់អាជ្ញាបណ្ណបាហុនិក។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី(នៅទីស្ដីការគណៈរដ្ឋមន្ត្រី)។ |
| ៣ | **០៣/៩/២០<br>ម៉ោង០៩:៣០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយសម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្ដមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងពិភាក្សាលើ៖<br>១- សេចក្ដីព្រាងច្បាប់ស្ដីពីមូលបត្ររដ្ឋ។<br>២- សេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា<br>៣.២- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីវិនិយោគរវាងបណ្ដារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.៣- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទីមួយវិសោធនកម្មកិច្ចព្រមព្រៀង ស្ដីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន<br>៣.៤- សេចក្ដីព្រាងច្បាប់ ស្ដីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្ដីពីសេវាកម្ម |

| | | |
|---|---|---|
| | | ៣.៥- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកការផ្តល់អាជ្ញាបណ្ណបាហុនិកា។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៤ | ០៤/៩/២០<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម ៖<br>១- សេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ។<br>២- សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។<br>៣- បញ្ហាផ្សេងៗ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិលើ៖<br>៣.១- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសាធារណរដ្ឋឥណ្ឌា<br>៣.២- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីវិនិយោគរវាងបណ្តារដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន<br>៣.៣- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីមួយវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន<br>៣.៤- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម<br>៣.៥- សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងអាស៊ានស្តីពីការទទួលស្គាល់ទៅវិញទៅមកការផ្តល់អាជ្ញាបណ្ណបាហុនិកា។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី (វិមានសន្តិភាព)។ |
| ៥ | ០៤/៩/២០<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំការងារជាមួយក្រុមហ៊ុនចិន ដើម្បីផ្តល់ព័ត៌មានបច្ចេកទេសនិងធុរកិច្ចដល់ក្រុមហ៊ុនចិន។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៦ | ១០/៩/២០<br>ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំចង្អៀតក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកក្កដា។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| ៧ | ២៩/៩/២០<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងវេទិកាផ្សព្វផ្សាយស្តីពីការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាពសដ៏ខ្ពង់ខ្ពស់ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ (នៅទីស្តីការគណៈរដ្ឋមន្ត្រី សាលប្រជុំC)។ |

## ពន្យល់ពាក្យ

ព្រៃ ន : ប្រទេស ឬទីដីដែលមានរុក្ខជាតិ លតាជាតិ តិណជាតិ ដុះដេរដាស ទ្រុបទ្រុល។ ឧទាហរណ៍: ព្រៃតូច ព្រៃធំ។

ពហុភាពនៃព្រៃ :

ក)- ប្រភេទព្រៃក្នុងន័យទូទៅ:

| | | |
|---|---|---|
| ១- ព្រៃរនាម | = | ព្រៃក្នុងបឹង ឬក្នុងទីដែលមានទឹកលិចត្រាំនៅយូរ។ |
| ២- ព្រៃរបោះ ឬព្រៃល្បោះ | = | ព្រៃដែលមានដើមឈើដុះរង្វើលៗ។ |
| ៣- ព្រៃរលោង | = | ព្រៃដែលដុះខ្ពស់ស្រឡះក្នុងទីទំនាប។ |
| ៤- ព្រៃស្រោង | = | ព្រៃក្នុងទីខ្ពស់ដែលមានដើមឈើដុះខ្ពស់ស្រឡេវ។ |
| ៥- ព្រៃហ៊ាតព្រៃហោង | = | ព្រៃធំដែលឆ្ងាយដាច់ស្រយាលពីស្រុកភូមិគួរឱ្យស្ញើប គួរឱ្យសៀម ព្រោះមានសត្វរូវចាំបៀតបៀន។ |
| ៦- ព្រៃផ្សៃ | = | ព្រៃតូចៗ ព្រៃរាយរង។ |
| ៧- ព្រៃជាំ | = | ព្រៃចាស់ដែលមានជាតិសើមជានិច្ច។ ព្រៃនេះច្រើនមានទាកក្នុងពេលភ្លៀងម្តងៗ។ |
| ៨- ព្រៃញៀត | = | ព្រៃដែលញឹកជ្រៀតជុកជិតដោយស្មៅ ស្បូវ កូនឈើណែនពីខាងក្រោម។ |
| ៩- ព្រៃគុម្ពោត | = | ព្រៃឈើដែលដុះដុបៗ ដោយដុះមើលទៅជ្រុំដង្ហំជិត។ |
| ១០- ព្រៃភ្នំ | = | ព្រៃឈើដែលដុះលើភ្នំ និងជើងភ្នំ។ |
| ១១- ព្រៃស្បាត | = | ព្រៃដែលដុះញឹកជិតទ្រុបទ្រុល។ |

ខ)- ព្រៃក្នុងន័យធៀប៖

ព្រៃ គុ. : ដែលកើត ដែលមាននៅក្នុងព្រៃ៖ សត្វព្រៃ ក្របីព្រៃ គោព្រៃ ឆ្កែព្រៃ ជ្រូកព្រៃ មាន់ព្រៃ មនុស្សព្រៃ... ។

ព្រៃៗ ព.ប្រ : ដែលមានបែបបទ ឬសណ្តាប់ធ្នាប់ឆ្គង ធ្វេងៗ ៖ ឬកព្រៃៗ សំដីព្រៃៗ និយាយព្រៃៗ។ ដែលនាំឱ្យទើសគំនិត ឱ្យចង្អៀតគំនិត ៖ នាំឱ្យព្រៃគំនិត។

ព្រៃងារ ន. : ជនជាតិវេស្ស ឬវេស្សៈ(ក្នុងកម្ពុជប្រទេសមានតែរជ្ជកាលអំពីដើម )។ ព.ផ្ទ. អ្នកងារ។

ព្រៃអង្គរ គុ. : (ព.ក្ល ពីព្រៃនគរ) ជាឈ្មោះនៃព្រៃនៅជិតមាត់បឹង មានច្រើនតំបន់នៅខេត្តក្រៅរបស់ប្រទេសកម្ពុជា គេហៅបឹងខ្លះថា បឹងព្រៃអង្គរ។

គ)- ប្រភេទពាក្យព្រៃ ដែលប្រើពីមុខឈ្មោះខេត្ត ស្រុក ឃុំ ៖

| | |
|---|---|
| ១- ព្រៃវែង | ឈ្មោះខេត្តមួយរបស់កម្ពុជរដ្ឋ |
| ២- ព្រៃកប្បាស | ឈ្មោះស្រុកមួយនៅក្នុងខេត្តតាកែវ |
| ៣- ព្រៃឈរ | ឈ្មោះស្រុកមួយនៅក្នុងខេត្តកំពង់ចាម |
| ៤- ព្រៃនប់ | ឈ្មោះស្រុកមួយនៅក្នុងខេត្តព្រះសីហនុ |
| ៥- ព្រៃនគរ | ឈ្មោះក្រុងជាទីប្រជុំកិច្ចការនៃរាជការធំនៅក្នុងដែនដីកម្ពុជាក្រោម |
| ៦- ព្រៃល្វា | ឈ្មោះឃុំមួយក្នុងស្រុកព្រៃកប្បាសខេត្តតាកែវ |

| | |
|---|---|
| ៧- ព្រៃផ្តៅ | ឈ្មោះឃុំមួយក្នុងស្រុកអង្គរបូរីខេត្តតាកែវ |
| ៨- ព្រៃយុថ្កា | ឈ្មោះឃុំមួយក្នុងស្រុកកោះអណ្តែតខេត្តតាកែវ |
| ៩- ព្រៃខ្លា | ឈ្មោះឃុំមួយក្នុងស្រុកកោះអណ្តែតខេត្តតាកែវ |
| ១០- ព្រៃស្លឹក | ឈ្មោះឃុំមួយក្នុងស្រុកទ្រាំងខេត្តតាកែវ |
| ១១- ព្រៃរំដេង | ឈ្មោះឃុំមួយក្នុងស្រុកគីរីវង់ខេត្តតាកែវ |
| ១២- ព្រៃអំពក | ឈ្មោះឃុំមួយក្នុងស្រុកគីរីវង់ខេត្តតាកែវ |
| ១៣- ព្រៃស | ឈ្មោះសង្កាត់មួយក្នុងរាជធានីភ្នំពេញ |
| ១៤- ព្រៃញី | ឈ្មោះសង្កាត់មួយក្នុងក្រុងពោធិ៍សាត់ |
| ១៥- ព្រៃជ្រូក | ឈ្មោះឃុំមួយក្នុងស្រុកពួកខេត្តសៀមរាប |
| ១៦- ព្រៃគុយ | ឈ្មោះឃុំមួយក្នុងស្រុកកំពង់ស្វាយខេត្តកំពង់ធំ |
| ១៧- ព្រៃតាហ៊ូ | ឈ្មោះសង្កាត់មួយក្នុងស្រុកស្ទឹងសែនខេត្តកំពង់ធំ |
| ១៨- ព្រៃគ្រី | ឈ្មោះឃុំមួយក្នុងស្រុកជលគីរីខេត្តកំពង់ឆ្នាំង |
| ១៩- ព្រៃមូល | ឈ្មោះឃុំមួយក្នុងស្រុករលាប្អៀរខេត្តកំពង់ឆ្នាំង |
| ២០- ព្រៃខ្ពស់ | ឈ្មោះឃុំមួយក្នុងស្រុកបវេលខេត្តបាត់ដំបង |
| ២១- ព្រៃចាស់ | ឈ្មោះឃុំមួយក្នុងស្រុកឯកភ្នំខេត្តបាត់ដំបង |
| ២២- ព្រៃស្វាយ | ឈ្មោះឃុំមួយក្នុងស្រុកមោងឫស្សីខេត្តបាត់ដំបង |
| ២៣- ព្រៃតូច | ឈ្មោះឃុំមួយក្នុងស្រុកមោងឫស្សីខេត្តបាត់ដំបង |
| ២៤- ព្រៃត្រឡាច | ឈ្មោះឃុំមួយក្នុងស្រុករុក្ខគីរីខេត្តបាត់ដំបង |
| ២៥- ព្រៃឃ្នេស | ឈ្មោះឃុំមួយក្នុងស្រុកមេសាងខេត្តព្រៃវែង |
| ២៦- ព្រៃរំដេង | ឈ្មោះឃុំមួយក្នុងស្រុកមេសាងខេត្តព្រៃវែង |
| ២៧- ព្រៃទទឹង | ឈ្មោះឃុំមួយក្នុងស្រុកស៊ីធរកណ្តាលខេត្តព្រៃវែង |
| ២៨- ព្រៃដើមថ្នឹង | ឈ្មោះឃុំមួយក្នុងស្រុកស៊ីធរកណ្តាលខេត្តព្រៃវែង |
| ២៩- ព្រៃខ្លា | ឈ្មោះឃុំមួយក្នុងស្រុកស្វាយអន្ទរខេត្តព្រៃវែង |
| ៣០- ព្រៃព្នៅ | ឈ្មោះឃុំមួយក្នុងស្រុកពារាំងខេត្តព្រៃវែង |
| ៣១- ព្រៃស្នៀត | ឈ្មោះឃុំមួយក្នុងស្រុកពារាំងខេត្តព្រៃវែង |
| ៣២- ព្រៃស្រឡិត | ឈ្មោះឃុំមួយក្នុងស្រុកពារាំងខេត្តព្រៃវែង |
| ៣៣- ព្រៃឈរ | ឈ្មោះឃុំមួយក្នុងស្រុកកំពង់ត្របែកខេត្តព្រៃវែង |
| ៣៤- ព្រៃពោន | ឈ្មោះឃុំមួយក្នុងស្រុកកំពង់ត្របែកខេត្តព្រៃវែង |
| ៣៥- ព្រៃចារ | ឈ្មោះឃុំមួយក្នុងស្រុកជើងព្រៃខេត្តកំពង់ចាម |
| ៣៦- ព្រៃពួច | ឈ្មោះឃុំមួយក្នុងស្រុកអង្គស្នួលខេត្តកណ្តាល |
| ៣៧- ព្រៃញៀត | ឈ្មោះឃុំមួយក្នុងស្រុកគងពិសីខេត្តកំពង់ស្ពឺ |
| ៣៨- ព្រៃវិហារ | ឈ្មោះឃុំមួយក្នុងស្រុកគងពិសីខេត្តកំពង់ស្ពឺ |
| ៣៩- ព្រៃរំដួល | ឈ្មោះឃុំមួយក្នុងស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ |
| ៤០- ព្រៃក្មេង | ឈ្មោះឃុំមួយក្នុងស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ |
| ៤១- ព្រៃក្រសាំង | ឈ្មោះឃុំមួយក្នុងស្រុកឧដុង្គខេត្តកំពង់ស្ពឺ |

**ឃ)- ប្រភេទព្រៃក្នុងន័យវប្បធម៌ សេដ្ឋកិច្ច និងបរិស្ថានៈ**

**១-ព្រៃការពារ** គឺជាព្រៃដែលមានមុខងារចម្បងសម្រាប់ការពារប្រព័ន្ធមជ្ឈដ្ឋានជាអាទិ៍ រក្សានីយតភាពនៃប្រភពទឹក អភិរក្សជីវចម្រុះ អភិរក្សដីទឹក ទីជម្រាល តំបន់ផ្ទៃរងទឹកភ្លៀង ជម្រកសត្វព្រៃ មច្ឆាជាតិ រាំងទឹកជំនន់ ការពារការហូរច្រោះ រាំងការទន្ទ្រានទឹកសមុទ្រ រក្សាជីវជាតិដី ឬមានតម្លៃសម្រាប់សម្បត្តិវប្បធម៌ដែលបម្រើប្រយោជន៍សាធារណៈ។ ព្រៃការពារមិនបញ្ចូលនូវតំបន់ការពារធម្មជាតិ ក្រោមយុត្តាធិការនៃក្រសួងបរិស្ថាន អនុឡោមតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិឡើយ។

**២-ព្រៃគុប** គឺជាផ្ទៃដីព្រៃឈើប្រភេទព្រៃផ្តល់ផលដែលកំណត់ដោយភូមិសាស្ត្រជាក់លាក់និងបង្កើតជាមូលដ្ឋាននៃ "ផ្ទៃដីប្រមូលផលព្រៃឈើប្រចាំឆ្នាំ" នីមួយៗកំណត់នៅក្នុងផែនការគ្រប់គ្រងព្រៃសម្បទាន និងផែនការប្រមូលផលប្រចាំឆ្នាំ។

**៣-ព្រៃឈើ** គឺជាឯកតានៃប្រព័ន្ធមជ្ឈមណ្ឌលធម្មជាតិ ឬសិប្បនិមត្តិ ក្រោមទម្រង់ជាដីសើម ដីលិចទឹក ឬដីស្ងួតដែលគ្រប់ដណ្តប់ដោយរុក្ខជាតិចម្រុះ ទោះបីដុះដោយធម្មជាតិក្តី ឬដោយដាំក្តី រួមទាំងធនធានសត្វព្រៃ និងធនធានធម្មជាតិដទៃ ដែលស្ថិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺជាផលអនុផលព្រៃឈើ ឬសេវាកម្មផ្តល់ដោយព្រៃឈើ។ ពុំត្រូវចាត់ទុកជាព្រៃឈើតាមន័យរបស់ច្បាប់ស្តីពីព្រៃឈើ គឺដីដែលបានកំណត់ដោយរដ្ឋជាដីកសិកម្មស្តែរួមមាន ចម្ការ ដីទំនេរសម្រាប់ផលិតកម្មកសិកម្មក្រៅពីផលឈើ ដីក្នុងតំបន់ឧស្សាហកម្ម និងដីសម្រាប់នគរូបនីយកម្មនិងសំណង់។

**៤-ព្រៃបម្រុងទុកអចិន្ត្រៃយ៍** គឺជាព្រៃរដ្ឋគ្រប់ដណ្តប់លើដីដែលមិនមែនជាកម្មសិទ្ធិឯកជន និងត្រូវបានចាត់ថ្នាក់ជាព្រៃផ្តល់ផល ព្រៃការពារ និងផ្ទៃដីព្រៃសម្រាប់ផ្លូវដើម្បីគោលបំណងអភិវឌ្ឍផ្សេងទៀត។

**៥-ព្រៃផ្តល់ផល** គឺជាតំបន់ព្រៃដែលមានមុខងារចម្បងសម្រាប់ផលិតកម្មផលព្រៃឈើ ប្រកបដោយនិរន្តរភាព។ ព្រៃផ្តផលរួមមាន ព្រៃសម្បទាន ព្រៃអនុញ្ញាតឱ្យធ្វើអាជីវកម្ម ព្រៃរិចរិល តំបន់ព្រៃឈើត្រូវស្តារឡើងវិញ តំបន់បម្រុងទុកសម្រាប់ការបន្តពូជព្រៃឈើ ឬចម្ការ ព្រៃឈើតំបន់ដាំព្រៃឈើឡើងវិញ និងតំបន់ព្រៃឈើស្ថិតក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើនិងសហគមន៍មូលដ្ឋាន។

**៦-ព្រៃលិចទឹកនិងព្រៃកោងកាង** គឺជាឯកតានៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬសិប្បនិមិត្ត ក្រោមទម្រង់ជាដីលិចទឹកដែលគ្រប់ដណ្តប់ដោយរុក្ខជាតិចម្រុះ ទោះបីដុះដោយធម្មជាតិ ឬដោយដាំក្តី រួមទាំងធនធានធម្មជាតិដទៃដែលស្ថិតក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺជាជម្រកពងកូនរបស់ត្រី ព្រមទាំងវារីសត្វទាំងអស់។ ពុំត្រូវចាត់ទុកថាជាព្រៃលិចទឹក ឬព្រៃកោងកាងរួមមានដំណាំកសិកម្ម ឬដំណាំឧស្សាហកម្មនិងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍។

**៧-ព្រៃសម្បទាន** គឺជាតំបន់ព្រៃឈើណាមួយដែលរាជរដ្ឋាភិបាលបានផ្តល់ទៅឱ្យក្រុមហ៊ុនឯកជនតាមរយៈការចរចា ឬដេញថ្លៃនូវសិទ្ធិនិងការទទួលខុសត្រូវលើការគ្រប់គ្រងនិងប្រមូលផលលើផ្ទៃដីកំណត់សមស្របទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់និងលិខិតបទដ្ឋានផ្សេងៗ។

**៨-ព្រៃសម្បទានិក** គឺជានីតិបុគ្គល ឬជាអង្គភាពស្របច្បាប់ជាតិ ឬបរទេស ដែលត្រូវផ្តល់សិទ្ធិប្រើប្រាស់ចំពោះព្រៃសម្បទានដោយរដ្ឋ តាមរយៈដំណើរការដេញថ្លៃជាសាធារណៈស្របច្បាប់។

**៩-ព្រៃសហគមន៍** គឺជាព្រៃរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងមួយរវាងនាយកដ្ឋានរដ្ឋបាលព្រៃឈើជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬក្បែរព្រៃ ដែលពឹងផ្អែកលើព្រៃឈើសម្រាប់ការចញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី ហើយដែលបានព្រមព្រៀងធ្វើការគ្រប់គ្រងនិងប្រើប្រាស់ព្រៃឈើនោះ ប្រកបដោយនិរន្តរភាព។

**១០-ព្រៃឯកជន** គឺជាចម្ការឈើដែលបានដាំ ឬដើមឈើដែលដុះដោយធម្មជាតិលើដីដែលបានចុះបញ្ជីការ និងផ្តល់ជាកម្មសិទ្ធិឯកជន ក្រោមនីតិវិធីនិងច្បាប់រដ្ឋ។

# ស្រាវជ្រាវ : យល់ដឹងអំពីពាក្យ " ក្រមសីលធម៌ "

## ក) ផ្ដើមសេចក្ដី

ពាក្យថា ក្រមសីលធម៌ ឬ ទស្សនវិជ្ជាសីលធម៌ ឬ សីលធម៌ ដែលត្រូវនឹងពាក្យអង់គ្លេសថា Ethics ក្លាយមកពីពាក្យក្រិកថា Ethos ដែលមានន័យថា ទំនៀមទំម្លាប់ អត្តចរិត របៀបរបប ឬក៏អារម្មណ៍។

ក្រមសីលធម៌ត្រូវបានគេកំណត់និយមន័យថា ជាការសិក្សាអំពីអ្វីដែលត្រូវឬខុស នៅក្នុងទង្វើរបស់មនុស្សនិងជាការស្វែងរកជីវិតប្រកបដោយកុសល។គឺជាការសិក្សាសំខាន់ទៅលើក្រមសីលធម៌ក្បួនច្បាប់នៃការប្រព្រឹត្ត( Moral Code ) ឬប្រព័ន្ធផ្សេងៗដែលគួរត្រូវបានគេប្រព្រឹត្តល្អ និងអ្វីដែលជាការប្រព្រឹត្តមិនល្អ។

សីលវិជ្ជាបង្ហាញនូវអំពីល្អរបស់មនុស្សដែលគួរយកគំរូតាម និងអំពីអាក្រក់របស់មនុស្សដែលមិនគួរអនុវត្តតាម។ ដូចនេះ សីលវិជ្ជាផ្ដល់ឱ្យយើងនូវគំរូមួយដែលផ្អែកលើមូលដ្ឋាននេះ យើងអាចដឹងថា តើអាកប្បកិរិយារបស់យើងប្រកបដោយសីលធម៌ត្រឹមត្រូវ ប្រកបដោយគុណធម៌ និងគួរឱ្យចង់បានឬមិនគួរឱ្យចង់បាន។

ពាក្យថា សីលធម៌ បើតាមធម្មតាត្រូវបានគេយល់ថា មានន័យដូចគ្នានឹងពាក្យសីលវិជ្ជាដែរ។ ប៉ុន្តែ បើតាមលក្ខណៈបច្ចេកទេស សីលធម៌សំដៅយកការប្រព្រឹត្តផ្ទាល់របស់បុគ្គល។ សីលធម៌ត្រូវបានអនុវត្តដោយមនុស្សនូវគោលការណ៍សីលធម៌ឬក៏ក្រមនៃការប្រព្រឹត្តដែលគេបានចេះដឹងបានយល់ព្រមទទួលយកបានទទួលនូវជំនឿ អាកប្បកិរិយា ឬគំរូដោយឡែក បានប្រតិបត្តិនៅក្នុងការរស់នៅប្រចាំថ្ងៃ និងបង្ហាញឱ្យឃើញតាមការសម្រេចចិត្ត និងអំពើរបស់គេ។

ទោះបីមានការពន្យល់បែបណាក៏ដោយ ក៏ពាក្យ សីលវិជ្ជា( Ethics ) និងពាក្យ សីលធម៌( Moral ) នៅតែរក្សាន័យស្រដៀងគ្នាដដែល ដោយហេតុថា ពាក្យទាំងពីរនេះសុទ្ធតែទាក់ទងទៅនឹងការប្រព្រឹត្តរបស់មនុស្ស ជាពិសេស ទាក់ទងទៅនឹងគុណភាព ឬលក្ខណៈនៃការប្រព្រឹត្តដែលធ្វើឱ្យគេអាចទទួលយកបាន ហើយនឹងក្លាយទៅជាទម្លាប់នៅក្នុងចំណោមសមាជិកសង្គមមួយ។

## ខ) ភាពចាំបាច់នៃក្រមសីលធម៌

ហេតុអ្វីបានជាយើងត្រូវសិក្សាក្រមសីលធម៌ ?

បញ្ហាសំខាន់មួយដែលត្រូវបានគេជ្រើសយកជាអាទិភាព គឺទាក់ទងនឹងសំណួរថា "ហេតុអ្វីបានជាក្រមសីលធម៌មានភាពចាំបាច់នៅក្នុងសង្គម និងជាមុខវិជ្ជាមួយចាំបាច់ក្នុងការសិក្សានៅសកលវិទ្យាល័យ និងនៅសាលាជាន់ខ្ពស់ ?" អំណោះអំណាងដែលថា ការសិក្សាក្រមសីលធម៌គឺជាតម្រូវការមូលដ្ឋានក្នុងកម្មវិធីសិក្សាភាគច្រើននោះ នោះគឺជាការបង្ហាញនូវតម្លៃដែលផ្ដល់ឱ្យដោយអ្នកអប់រំនានា ចំពោះផ្នែកសំខាន់នៃក្រមសីលធម៌។ និយាយឱ្យចំទៅការអប់រំក្រមសីលធម៌ គឺជាការអភិវឌ្ឍមនុស្សឱ្យក្លាយទៅជាមនុស្សល្អ ដូចនេះគេមិនគួរមើលរំលងក្រមសីលធម៌ទេ បានសេចក្ដីថា បើមិនបានអប់រំមុខវិជ្ជានេះទេ មនុស្សដែលផលិតចេញទៅ ចំណេះដឹងរបស់គេ អាចនឹងត្រូវគេយកទៅប្រើក្នុងបំណងអាក្រក់ ប្រាសចាកសីលកុសល ដូចជាការប្រកាន់យកឥរិយាបថអត្តទត្តភាព( egoiste ) ។

នៅមានហេតុផលជាច្រើនណាស់ដែលបានគាំទ្រថាក្រមសីលធម៌មានភាពចាំបាច់ចំពោះសង្គមមនុស្ស។ ហេតុផលស្នើឡើងដោយលោក ធីថឹស( Titus ) ខាងក្រោមនេះមានលក្ខណៈគ្រប់គ្រាន់ធ្វើឱ្យយើងឃើញនូវសារៈសំខាន់នៃក្រមសីលធម៌៖

១- យើងរស់នៅក្នុងពិភពលោក មិនមែនគ្រាន់តែជាកន្លែងដែលយើងធ្វើការសម្រេចចិត្តនោះទេ ប៉ុន្តែជាកន្លែងដែលមានផ្លូវល្អនិងផ្លូវអាក្រក់ផ្សេងៗផងដែរ។សីលវិជ្ជាពិតជាប្រាប់យើងយ៉ាងច្បាស់ថាហេតុអ្វីបានជាអំពើមួយល្អប្រសើរជាងអំពើមួយទៀត។

៣-អំពើសីលធម៌ និងប្រព័ន្ធក្រមសីលធម៌ ទាំងក្នុងអតីតកាល និងក្នុងបច្ចុប្បន្នកាល ប្រាកដជាត្រូវបានគេរិះគន់ និងវាយតម្លៃប្រកបដោយបញ្ញា។ ផ្នែកខ្លះនៃឥរិយាបថ និងប្រព័ន្ធសីលវិជ្ជាបង្ហាញពីតម្រូវការរបស់មនុស្ស ឯផ្នែកខ្លះទៀតមិនបានបង្ហាញពីតម្រូវការរបស់មនុស្សទេ។ ផ្នែកខ្លះជាជំនួយនៃសីលកុសលក្នុងការរស់នៅប្រចាំថ្ងៃ ឯផ្នែកខ្លះទៀតជាឧបសគ្គយ៉ាងធ្ងន់ធ្ងរ។

៤-ក្រមសីលធម៌ព្យាយាមបង្ហាញមនុស្សនូវតម្លៃពិតនៃជីវិតក្រមសីលធម៌ប្រឹងប្រែងបង្កើតន័យសីលធម៌របបគំហើញពីតម្លៃនៃជីវិត និងញ៉ាំងមនុស្សឱ្យរួមគ្នាក្នុងការស្វែងរកនូវតម្លៃទាំងនោះ។

តាមរយៈអំណះអំណាងនេះ យើងឃើញថា ក្រមសីលធម៌ពិតជាមានសារសំខាន់ណាស់ ក្នុងការជួយទ្រទ្រង់សង្គមមនុស្សឱ្យរស់នៅប្រកបដោយសណ្តាប់ធ្នាប់ចេះគោរពគ្នាទៅវិញទៅមកចេះអត់អោនគ្នានិងចេះជួយគ្នាក្នុងគ្រាមានអាសន្ន។ពិតមែនហើយថាក្រមសីលធម៌មិនមែនជាច្បាប់រដ្ឋដែលបង្ខំមនុស្សឱ្យត្រូវតែគោរពដាច់ខាតនោះទេ ប៉ុន្តែយើងគួរកត់សម្គាល់ថា សមាជិក សហគមន៍ សង្គមមួយ ដែលគោរពតាមក្រមសីលធម៌ភាគច្រើននៃពួកគេ ក៏ជាអ្នកគោរពច្បាប់រដ្ឋផងដែរ។

សរុបសេចក្តីមកយើងអាចនិយាយបានថាប្រជាជាតិខ្មែរក៏ដូចជាប្រជាជាតិនានាទូទាំងពិភពលោកដែរ នៅពេលដែលខ្មែរម្នាក់ៗស្គាល់តម្លៃពិតនៃសីលធម៌គោរពច្បាប់សីលធម៌គោរពច្បាប់រដ្ឋនិងគោរពសិទ្ធិមនុស្សបានល្អប្រពៃ នោះខ្មែរយើងពិតជាអាចក្លាយទៅជាពលរដ្ឋល្អដែលមិនគ្រាន់តែរស់នៅក្នុងនាមជាមនុស្សប៉ុណ្ណោះទេ ប៉ុន្តែខ្មែរយើងថែមទាំងរស់នៅក្នុងនាមជាពលរដ្ឋជាកម្លាំងរបស់រដ្ឋ ដែលអាចជួយកសាងនិងការពារប្រទេសឱ្យសំបូររុងរឿង និងធ្វើឱ្យសង្គមជាតិប្រកបដោយសន្តិភាព ស្ថិរភាព សណ្តាប់ធ្នាប់ យុត្តិធម៌ និងសុខុដុមរមនា។

សម្គាល់៖

វត្ថុនិងសត្វមិនមានសីលធម៌ ហើយក៏មិនអសីលធម៌ដែរ ពីព្រោះពួកវាគ្មានសីលញាណ (moral conscience ) និងឆន្ទៈ។ មានតែមនុស្សទេដែលជាភាវៈប្រកបដោយសីលធម៌ (a moral being ) ពីព្រោះមនុស្សជាភាវៈមានទំនួលខុសត្រូវ និងមានវិចារណញ្ញាណ។ មនុស្សមិនអាចទទួលខុសត្រូវទាំងស្រុងចំពោះសុខភាព ឬភាពក្រីក្ររបស់ខ្លួនទេ ក៏ដូចជាមិនទទួលខុសត្រូវ ទាំងស្រុងចំពោះទេពកោសល្យសិល្បៈ រូបរាងវិចារណញ្ញាណរបស់គេដែរ។ ប៉ុន្តែមនុស្សតែងតែទទួលខុសត្រូវចំពោះឥរិយាបថសីលធម៌របស់ខ្លួន។

តាមពិតក្រមសីលធម៌គ្រប់គ្រងផ្នែកទាំងមូលនៃជីវិត ពោលគឺមិនមែនគ្រាន់តែជាផ្នែកណាមួយ ឬសកម្មភាពពិសេសណាមួយនៃជីវិតប៉ុណ្ណោះទេ។ បញ្ហាសីលធម៌មិនមែនជាបញ្ហាសីលធម៌តែឯកឯងទេ វាជាបញ្ហាបុគ្គល សង្គម សេដ្ឋកិច្ច នយោបាយ ឬបញ្ហាអន្តរជាតិផងដែរ។ មូលដ្ឋាននៃក្រមសីលធម៌ គឺទស្សនវិជ្ជាដែលនឹងមានបរិយាយលម្អិតអំពីបញ្ហានេះ។



## ឧកញ៉ា
### (បទពាក្យ៧)

ពិភពភ័ន្តប្រែប្រួលធាតុអាកាស
សង្គមប្តូរផ្លាស់គោរម្យងារ
ផ្តល់គុណបំណាច់ជូនជនា
កសាងការពារមាតុភូមិ។
ទទួលបានងារជាឧកញ៉ា
កិត្តិយសថ្លៃថ្លាខ្ពស់ឧត្តម
រីកមុខរីកមាត់ក្នុងសង្គម
ចាត់ចូលជំនុំក្រុមជាន់ខ្ពស់។
ពីមុនឧកញ៉ាឡើងតាមពង្ស
ឥលូវផ្លាស់ទ្រង់តាមកេរ្តិ៍ឈ្មោះ
គួបផ្សំទឹកប្រាក់លើកកម្ពស់
ពុះពារស្វាស្វះជួយភាគទាន។
សង់កុដិសាលាត្រពាំងស្រះ
ចូលរួមជំនះគ្រោះអត់ឃ្លាន
លើកផ្លូវទំនប់អណ្តូងស្ពាន
ប្រឡាយព្រាងលានដល់កសិករ។
អគុណឧកញ៉ាដ៏សប្បុរស
បរិច្ចាគរំដោះភាពក្រីក្រ
ធ្វើឱ្យកម្ពុជាស្រស់បវរ
អប់អរស្នាដៃថ្លៃវិសេស។
សម្តេចតែជាពិតត្រូវការ
សេដ្ឋីឧកញ៉ាស្តារស្រុកទេស
ប៉ុន្តែសូមចិត្តកុំបីធ្វេស
យកការប្រទេសជាស្ងួនគួ។

សួនកំណាព្យ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## អ្នកមានអ្នកក្រ
### (ព្រហ្មគីតិ)

អ្នកមានរក្សាខ្សត់
ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ
ដូចសំពៅនូវសំប៉ាន។
អ្នកខ្ពស់រក្សាទាប
ដោយសភាពពីបុរាណ
អ្នកឆ្អែតរក្សាឃ្លាន
នាអ្នកមានរក្សាផ្ទារ។
រក្សាទៅមុខរឹង
ឥតកំដឹងអស់អម្បាល
ចំណេរចីរកាន់កាល
ដូចរបងស្រាស់បន្លា។
កុំឆ្អែតពេកតែឯង
មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានឃ្លានផ្ទៃផ្សា
ឱ្យស៊ីរ៉ាបានឆ្អែតផង។
កុំមានចិត្តលលើ
ពឹងក្រពើឱ្យចម្លង
កុំកាច់អុសរបង
រាំងចំណារឯអាត្មា។

ច្បាប់ពាក្យចាស់ - ព្រះសុគន្ធាធិបតី ជិម

## រឿងសិង្ហ និង កណ្ដុរ

ថ្ងៃមួយមានសិង្ហមួយដើរស្វែងរកចំណីស្រាប់តែប្រទះនឹងកណ្ដុរមួយក្បាលរត់មកប៉ះជើងហើយ កណ្ដុរក៏លាន់មាត់ថា៖

- យី បងសិង្ហមានជើងមាំៗណាស់ណ៎!

សិង្ហសំឡក់ចំមុខកណ្ដុរ រួចពោលថា៖

- ចុះឯងប្រញាប់ទៅណា បានជារត់មកប៉ះជើងអញ?

កណ្ដុរក៏តបទៅសិង្ហវិញថា៖

- នេះជាទម្លាប់របស់ពួកខ្ញុំទៅហើយ ទៅណាមកណាត្រូវតែលឿនរហ័ស ទើបពេលខ្លះបានជាភ្លាត់ស្នៀតប៉ះពាល់គេឯង។

សិង្ហនៅស្ងៀម កណ្ដុរក៏បន្តទៅទៀតថា៖

- ថ្វីត្បិតតែពួកខ្ញុំមានមាឌតូចល្អិត ជើងខ្លីក៏ពិតមែន ប៉ុន្តែបើបងសិង្ហឯងចង់ប្រឡងជាមួយខ្ញុំ ខ្ញុំក៏អាចកំដរបាន។

សិង្ហអត់មិនបានក៏តបថា៖

- ប្រយោកតែរូបខ្លួនឯងទៅ!

កណ្ដុរតម្លើងសំលេង ហើយតបទៅថា៖

- ចាំមួយភ្លែតណ៎ា បងនឹងបានឃើញថា ខ្ញុំខ្លាំងប៉ុនណា។

រំពេចនោះកណ្ដុរឱ្យសញ្ញាច្រេចៗ ហ្វូងកណ្ដុរក៏ចេញមកប្រមូលផ្ដុំគ្នាព័ទ្ធសិង្ហជុំជិត។ កណ្ដុរក៏តាំងស្រែកប្រកាសទៅថា៖

- ម៉េច បងសិង្ហឯងហ៊ានដែរឬអត់?

សិង្ហមិនឆ្លើយតបទៅវិញទេ លើកជើងដើរចេញទៅ ស្រាប់តែមានពពួកកញ្ជ្រោង សួរទៅសិង្ហថា៖

- អម្បាលអាសត្វកណ្ដុរប៉ុនអាចម៍សុច បងសិង្ហឯងមិនហ៊ានតតាំងនឹងវាដែរ?

សិង្ហឆ្លើយដោយទន់ភ្លន់ថា៖

-ពេលខ្លះយើងមិនគួរជ្រលក់ដៃជើងជាមួយពួកបង្ករឿងអស់នេះទេ ព្រោះថាបើយើងតបតនឹងវា គេថាយើងរំលោភសិទ្ធិរស់នៅ ហើយចំពោះភ្នែកអ្នកចាំរករឿងយើង គេថាជិះជាន់អ្នកតូចតាច ឯចំពោះខ្លួនយើងវាបាត់បង់កិត្តិយសទៅវិញទេ ដែលប្រយុទ្ធជាមួយដៃគូគ្មានទម្ងន់សោះ។

## រឿងឆ្លាតគ្រាន់បើ

ពេលមួយ មានក្រុមហ៊ុនមួយ ធ្វើសម្ភាសរើសបុគ្គលិកបម្រើការ៖

អ្នកសម្ភាស ៖ មើលលោក!តើមកសុំចូលធ្វើការនេះដើម្បីចង់បានប្រាក់ឬក៏ចង់បានកិត្តិយស?

បេក្ខជនទី១ ៖ បាទលោក! គឺខ្ញុំចង់បានប្រាក់ខែ។

អ្នកសម្ភាស ៖ សោកស្ដាយណាស់!លោកអាចទៅរកកន្លែងផ្សេងចុះ។ចុះចំណែកលោកខាងណោះវិញ ចង់បានអ្វីដែរ?

បេក្ខជនទី២ ៖ បាទលោក! គឺខ្ញុំចង់បានកិត្តិយសជាងប្រាក់។

អ្នកសម្ភាស ៖ ឆ្លាតណាស់! លោកឯងចេះទុកប្រាក់ឱ្យខ្ញុំ បើអញ្ចឹង ស្អែកមកធ្វើការចុះ។

# ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា

## ១. សេចក្តីផ្តើម

ប្រព័ន្ធទឹកសាបនៅកម្ពុជារួមមានទន្លេស្ទឹងព្រែកអូរប្រឡាយបឹងបួរត្រពាំងស្រះវាលទំនាបជាពិសេស ទន្លេមេគង្គចាប់ពីតំបន់ទឹកជួរក្រោមល្បាក់ខោនរហូតដល់បឹងទន្លេសាប និងតំបន់ ទំនាបខាងក្រោមដែលមាន ទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធតាមរបបទឹកទន្លេមេគង្គ និងទន្លេ ស្ទឹង ព្រែក អូរ ដែលពាក់ព័ន្ធ បង្កើត បានជាប្រព័ន្ធទឹកសាបដែលមានចរន្តទឹកហូរចូល និងហូរចេញពីបឹងបួរ វាល ទំនាបដ៏មានសក្តានុពលជាមូលដ្ឋាននៃ ប្រព័ន្ធអេកូឡូស៊ីដ៏ពិសិដ្ឋ ដែលគាំទ្រដល់លក្ខខ័ណ្ឌជីវសាស្រ្ត មច្ឆាជាតិជាច្រើនរយប្រភេទ ដែលធ្វើឲ្យប្រព័ន្ធ នេះក្លាយទៅជាមជ្ឈមណ្ឌលផលិតត្រីទឹកសាបធម្មជាតិ ច្រើនជាងគេក្នុងពិភពលោក។ ភាពសម្បូរបែប និង មាននៅគ្រប់ទីកន្លែងទូទាំងប្រទេសនៃត្រីទឹកសាបបានបង្កប់នូវសក្តានុពលថាមពលទ្រទ្រង់មនុស្សដែលរស់នៅ លើទឹកដីនេះឱ្យមានលទ្ធភាពយ៉ាងពេញលេញក្នុងការកសាងអរិយធម៌មជាតិសាសន៍ដ៏ខ្លាំងក្លាមួយតាំងពីពេល ចាប់ផ្តើមរបស់ប្រវត្តិសាស្រ្តនៃ មនុស្សជាតិ ដែលបច្ចុប្បន្ននេះ ការយល់ដឹងអំពីសារៈសំខាន់ជាគ្រឹះនៃធនធាន នេះ ពុំសូវមានអ្នកជំនាន់ក្រោយលើកយកមកពិចារណាឲ្យបានស៊ីជំរៅឡើយ។ ជាទូទៅយើងគ្រាន់ តែដឹងថា ភាពសម្បូរបែបនៃត្រីទឹកសាប បានជំរុញជនជាតិខ្មែរឲ្យចេះឆ្នៃប្រឌិតវាឱ្យទៅជាមូលដ្ឋាន ប្រូតេអ៊ីន ពីសាច់ សម្រាប់ទ្រទ្រង់ជីវភាពប្រចាំថ្ងៃជាប្រពៃណីនៃការបរិភោគ និងជាចំណែកមួយនៃវប្បធម៌ជាតិប៉ុណ្ណោះ ក៏ប៉ុន្តែ ធនធាននេះជាមូលដ្ឋានសេដ្ឋកិច្ចនិងសង្គមកិច្ចដែលជាគ្រឹះនៃការកកើតអរិយធម៌ដ៏រុងរឿងរបស់ជនជាតិខ្មែរ នាបូរាណសម័យ និងសម័យកាលក្រោយៗមកទៀតរហូតមកដល់សហសម័យ។

## ២. ការវិវត្តនៃប្រព័ន្ធអេកូឡូស៊ីទឹកសាបកម្ពុជាពីបុរេប្រវត្តិសាស្រ្តមកដល់បច្ចុប្បន្ន

ទន្លេមេគង្គមានប្រវែង ៤,២០០គីឡូម៉ែត្រ មានប្រភពដើមពីតំបន់ទីបេ ហូរឆ្លងកាត់តាមប្រទេសចិន មីយ៉ាន់ម៉ា ថៃឡង់ដ៏ ឡាវ កម្ពុជា និងវៀតណាម មុនហូរចាក់ចូលទៅសមុទ្រចិនខាងត្បូង។ ទន្លេនេះបានដើរតួ យ៉ាងសំខាន់ក្នុងប្រព័ន្ធទឹកសាបកម្ពុជា ដោយសារតែជំនួបរបស់វាជាមួយបឹងទន្លេសាប បានបង្កើតជាប្រព័ន្ធ អេកូឡូស៊ីខុសគេតែមួយគត់ក្នុងលោក ដែលគាំទ្រដល់ជីវសាស្រ្ត និងការបន្តពូជរបស់ត្រីរាប់រយប្រភេទ។ ដូច្នេះ ការចាប់អារម្មណ៍ដំបូងៗរបស់អ្នកវិទ្យាសាស្រ្ត គឺការស្វែងយល់ពីកំណរ កំណើតនៃបឹងនេះ និងទំនាក់ ទំនងវាជាមួយទន្លេមេគង្គដែលឧប្បត្តិកឡើងនូវបរិស្ថានដ៏ពិសិដ្ឋនេះ។ ក្រុមអ្នកវិទ្យាសាស្រ្ត ភូគព្ភសាស្រ្ត និង ភូមិសាស្រ្តបារាំង ដឹកនាំដោយលោក August Pavie (១៨៧៩-៨៥)[1] ហើយក្រោយមកទៀតក្រុមលោក Combannaire (១៩០៩)[2] បានសន្មតថា កាលពីប្រាំមួយពាន់មកប្រាំពាន់ឆ្នាំមុន នៅពេលដែលកម្ពស់ទឹក សមុទ្រខ្ពស់ជាងពេលនេះចំនួន ៨ម៉ែត្រនោះ ទំនាបកណ្តាលនៃប្រទេសកម្ពុជារួមទាំងតំបន់បឹងទន្លេសាប និង ភាគខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្នផងនោះ គឺជាឆកសមុទ្រមួយ ហើយទន្លេមេគង្គហូរចាក់ចូលឆកនេះ នៅត្រង់ចំណុចភ្នំសុពណ៌កាឡី ព្រំប្រទល់ខេត្តក្រចេះ និងខេត្តកំពង់ចាម។ ភស្តុតាងសំខាន់ៗពីរដែលធ្វើឱ្យ

[1] August Pavie, 1898. Recherches sur L’histoire du Cambodge, du Laos et du Siam.

[2] Combannaire, 1909. LÉtude du Pre-histoire du Cambodge.

មានការអះអាងដូច្នេះ គឺហ្វូស៊ីលនៅសំរោងសែន[3] ដែលស្ថិតនៅច្រាំងខាងកើតស្ទឹងជីនិត ក្នុងខេត្តខេត្តកំពង់ឆ្នាំង ដែលត្រូវបានគេចាត់ទុកថាជាភូមិនេសាទដំបូងនៅមាត់ពាម ដោយសារអ្នកភូគព្ភសាស្ត្រជីកកកាយរកឃើញសំបកលាស គ្រំ និងខ្ចងសមុទ្រ នៅជំរៅ១-១,៥ម៉ែត្រ (ជំរៅដែលរណាបទៅនឹងការប្រាប់ពីកាលបរិច្ឆេទនៃកាបោនដែលកំណត់អាយុកាលនៃទីតាំងជំរៅនេះនៅក្នុងចន្លោះប្រហែលពី១,៦៥០ឆ្នាំមក១២០ឆ្នាំមុនគ្រឹះសករាជ្យ ស្មើនឹង ៣,៦៧០ មក ២,១៣៩ឆ្នាំមុន ដែលមានអាយុកាលប្រហាក់ប្រហែលគ្នានឹងពេលដែលកំពស់ទឹកសមុទ្រកើនឡើង ៨ម៉ែត្រខ្ពស់ជាងបច្ចុប្បន្ន) និងការប្រទះឃើញ ឆ្លាម ម្ករ បបែល អន្ទង់សមុទ្រ (Anguila momarota) និងផ្សោតសមុទ្រយ៉ាងច្រើនដែលរស់នៅពាសពេញប្រព័ន្ធទឹកសាបនេះផងដែរ (សូមមើលរូបទី១)។




រូបទី១. ផែនទីបុរេប្រវត្តិសាស្ត្រដែលសន្និដ្ឋានពីស្ថានភាពភូមិសាស្ត្រប្រទេសកម្ពុជាកាលពី៦ពាន់ឆ្នាំមុន ដោយ លោក Auguste Pavie (ប្រភព: Auguste Pavie, 1898)

ការស្រាវជ្រាវមួយទៀតដែលដឹកនាំធ្វើនៅអំឡុងទសវត្សឆ្នាំ៩០ បានឲ្យដឹងថា កាលពីអំឡុងមួយម៉ឺនប្រាំពាន់(១៥,០០០)ឆ្នាំមុនកំពស់ទឹកសមុទ្រមានកំរិតទាបជាងកំពស់ទឹកសមុទ្របច្ចុប្បន្នចំនួន១២០ម៉ែត្រលុះមកដល់អំឡុងពេលប្រាំពីរពាន់(៧,០០០)ឆ្នាំមុន កំពស់ទឹកសមុទ្របានកើនឡើងមកដល់កំពស់ដែលកំពុងមាននាបច្ចុប្បន្ននេះ។ នៅពេលនោះបឹងទន្លេសាបនៅជាទីទំនាបរងទឹកភ្លៀងមួយ ដែលមានតែកូនបឹងតូចៗចំនួន៣ប៉ុណ្ណោះ ដែលទទួលទឹកពីតំបន់រងទឹកភ្លៀងនៃភ្នំក្រវាញ និងតំបន់រងទឹកភ្លៀងនៃភ្នំដងរែក ហើយនៅមិនមានទំនាក់ទំនងជាមួយទន្លេមេគង្គនៅឡើយ។ លុះមកដល់អំឡុង ពេលពី៦ពាន់មក៥ពាន់ឆ្នាំមុន កំពស់ទឹកសមុទ្របានកើនឡើងដល់៨ម៉ែត្រ ខ្ពស់ជាងកំពស់បច្ចុប្បន្ន ហើយបានជ្រៀតចូលទៅដីគោក ជួបជាមួយទន្លេមេគង្គនៅចំណុចខាងត្បូងភ្នំពេញ បង្កើតជាតំបន់ទឹកភ្លាវយ៉ាងធំ (ទំនាបខេត្តកណ្តាលខាងក្រោម ទំនាបខេត្តព្រៃវែង និងទំនាបខេត្តស្វាយរៀង និងភាគខាងត្បូងបំផុតនៃប្រទេសវៀតណាមបច្ចុប្បន្ន) ហើយរុញច្រានលំហូរទន្លេមេគង្គឲ្យងាកចូលទៅទីទំនាបបឹងទន្លេសាបតាមព្រែកតាមាក់ និងព្រែកដំបង កាត់តាមទំនាបកំពង់អុស និងទំនាបបាធាយ រួចបន្តទៅទំនាបស្រុកកំពង់លែង និងស្រុកជលគីរីនៃខេត្តកំពង់ឆ្នាំង និងទំនាបតាំងគោក-បារាយ នៃខេត្តកំពង់ធំ ហើយចាក់ចូលទៅទន្លេសាបត្រើយខាងកើតចាប់ពីចំណុចកំពង់អុសដល់ពាមល្វែក និងចាប់ពីមាត់ពាមស្ទឹងជីនិតដល់តំបន់ភ្នំនាងកង្រី ដែលធ្វើឲ្យទំនាបបឹងទន្លេសាបក្លាយទៅជាបឹងទឹកសាបដ៏ធំមួយ ដែលទទួលរបបទឹកពីទន្លេមេគង្គនៅរដូវវស្សា ហើយបញ្ចេញធារទឹកមកទន្លេមេគង្គវិញនៅរដូវប្រាំង (Tsukawaki, S., 1998)[4] ។

[3] ហ្វូស៊ីលជាច្រើនត្រូវបានត្រូវបានគេជីកកកាយរកផស្តុតាងតាំងពីឆ្នាំ១៨៨១ រហូតមកដល់ពេលថ្មីៗនេះ ចាប់ពីជំរៅ៦ម៉ែត្រដែលមានអាយុកាលប្រហែលនៅចុងយុគ្គសម័យកាលថ្មបំបែក និងដើមយុគ្គសម័យសំរិទ្ធឬលង្ហិន(ទង់ដែង) មកជំរៅតិចជាងមួយម៉ែត្រដែលមានអាយុកាលប្រហែល១២០០ឆ្នាំមុនប៉ុណ្ណោះ។

[4] Tsukawaki, S., 1998: Environmental changes in Lake Tonle Sap and the Mekong River system in Cambodia during the last 6,500 years. In: The first International Symposium on the Geoenvironmental changes and biodiversity in the Northeast Asia. Seoul, Korea, 16-19 November, 1998: 56-62.

នៅអំឡុងពេលបីពាន់ឆ្នាំចុងក្រោយនេះកំពស់ទឹកសមុទ្របានស្រកចុះប្រហែល៣-៤ម៉ែត្រដោយ បានដកខ្លួនពីដីគោកទៅនៅត្រឹមទំនាបទីក្រុងហូជីមិញបច្ចុប្បន្ន ដែលបង្កើតបានជាគន្លងផ្លូវទឹកថ្មី មួយតភ្ជាប់ទន្លេមេគង្គទៅបឹងទន្លេសាបត្រង់ចំណុចទន្លេចតុមុខ តាមរយៈដងទន្លេសាបដែលហូរកាត់ តាមរាជធានីភ្នំពេញ ខេត្តកណ្តាលភាគខាងជើង និងខេត្តកំពង់ឆ្នាំងនៅរដូវវស្សាចាប់ពីចុងខែឧសភាដល់ចុងខែកញ្ញាហើយបញ្ចេញធារទឹកមកទន្លេមេគង្គវិញតាមគន្លងផ្លូវដដែលចាប់ពីខែតុលាដល់ខែកុម្ភៈ។នៅក្នុងស្ថានភាពជាក់ស្តែងនៃកំពស់ទឹកសមុទ្រនាបច្ចុប្បន្ននេះ ចំណុចទន្លេចតុមុខបានក្លាយជា កន្លែងប្រសព្វគ្នារវាងទន្លេមេគង្គ និងទន្លេសាបមុនពេលហូរចុះទៅសមុទ្រចិនភាគខាងត្បូង តាមគន្លងផ្លូវ ទន្លេមេគង្គក្រោម និងទន្លេបាសាក់។ ទោះជាយ៉ាងនេះក៏ដោយ ក៏គន្លងផ្លូវទឹកដែលនាំទន្លេមេគង្គទៅជួបវាលទំនាបបឹងទន្លេសាបកាលពីប្រាំពាន់ឆ្នាំមុន នៅតែមានអត្ថិភាពដដែល នៅពេលទឹកជំនន់ទន្លេមេគង្គឡើងខ្ពស់បំផុតនៅរៀងរាល់ខែកញ្ញា (សូមមើលរូបទី២ ៣ និង៤)។




រូបទី២. បំរែបំរួលភូមិសាស្ត្រនិងបរិស្ថាននៃប្រព័ន្ធទឹកសាបកម្ពុជាពីបុរេប្រវត្តិសាស្ត្រមកដល់បច្ចុប្បន្ន
(ប្រភព: Shinji Tsukawaki, 1998)




រូបទី៣. កំរិតជ្រៀតចូលនៃទឹកសមុទ្រ ទៅក្នុងដីគោក កាលពី៥០០០ឆ្នាំ មុននៅលើផែនទីបច្ចុប្បន្ន។




រូបទី៤. កំរិតជ្រៀតចូលនៃទឹកសមុទ្រទៅក្នុងទៅដីគោក កាលពី៣០០០ឆ្នាំ មុននៅលើផែនទីបច្ចុប្បន្ន។

ប្រព័ន្ធទឹកហូរចូលហូរចេញនេះកើតឡើងនៅទូទាំងទីទំនាប ចាប់ពីខេត្តកំពង់ចាមរហូតដល់ដីសណ្តទន្លេមេគង្គដែលរាប់ពាន់ឆ្នាំក្រោយមកជីវៈចំរុះនៃប្រព័ន្ធទឹកសាបកម្ពុជាបានវិវត្តទៅជាបរិស្ថានធម្មជាតិដ៏ពិសិដ្ឋនៃរុក្ខជាតិលិចទឹក អណ្តែតទឹក និងក្នុងទឹកដែលជាមូលដ្ឋានគ្រឹះ នៃខ្សែចង្វាក់ចំណីអាហារនៃមច្ឆជាតិ ល្មូន

និងថនិកសត្វផ្សេងទៀត និងជាជំរកដ៏សុខដុមដែលជាកន្លែងពងកូនបន្តពូជ កន្លែងស៊ីចំណី និងជាកន្លែង សំងំលាក់ខ្លួនរបស់ពួកវាផងដែរ។ ការស្រាវជ្រាវចុងក្រោយនេះ បានបដិសេធការសន្មតមុនៗជាស្វ័យប្រវត្តដែលថា បឹងទន្លេសាបជាឆកសមុទ្រមួយ ដោយលទ្ធផលនៃការវិភាគសំណាកកំណកដីល្បាប់ដែលយកពី កន្លែងសង្ស័យទាំងអស់ ពុំឃើញមានសំណល់ ឬវត្ថុមានសារធាតុអ៊ីយ៉ូតដែលជាសារធាតុសមុទ្រ ប្រសិនបើកន្លែងទាំងនោះពិតជាធ្លាប់នៅក្រោមសមុទ្រមែន គឺត្រូវតែមានសេសសល់សារធាតុនេះក្នុងដីល្បាប់។ ឯសត្វសមុទ្រ ដូចជា ឆ្លាម ម្កុរ បបែល អន្ទង់សមុទ្រ ( Giant mottled eel ) ជាពិសេសសត្វផ្សោតក្បាលត្រងោល ( Ocaella brevirostris ) ( សត្វដែលមានលក្ខខ័ណ្ឌជីវសាស្ត្រអាចសម្រប និងបង្សាំខ្លួនបានលឿនទៅតាមបម្រែបម្រួលបរិស្ថានធម្មជាតិ ) ដែលឃើញនៅមានរស់នៅពាសពេញប្រព័ន្ធទឹកសាបកម្ពុជានោះ អាចប្រហែលជាសត្វទាំងនោះ ចូលតាមស៊ីចំណីនៅតំបន់ទឹកភ្លាវដែលសម្បូរចំណីកាលពីអំឡុង៥ពាន់ឆ្នាំមក៤ពាន់ឆ្នាំមុន ហើយជាប់ផុងខ្លួននៅទីនោះ នៅពេលដែលទឹកសមុទ្របានដកថយពីដីគោកមកនៅត្រឹមកំរិតបច្ចុប្បន្ននេះ កាលពី៣ពាន់ឆ្នាំមុន ហើយបានសម្រប និងបន្សាំខ្លួនរស់នៅពីស្ថានភាពបរិស្ថានទឹកភ្លាវ មកស្ថានភាពបរិស្ថានទឹកសាបទាំងស្រុង។ ឆ្លាម ម្កុរ និងបបែល ដែលតែងប្រទះឃើញមានច្រើនកាលពីគ្រាដំបូងៗ នៃឧស្សាហកម្មនេសាទទឹកសាបនោះ បច្ចុប្បន្ននេះស្ទើរតែដាច់ពូជទៅហើយ ដោយសារតែលក្ខខ័ណ្ឌបរិស្ថានទឹកសាប អាចគ្រាន់តែឱ្យពួកវារស់នៅធំធាត់បាន តែមិនអំណោយដល់ការបន្តពូជឡើយ។ ឯអន្ទង់សមុទ្រដែលជាប្រភេទសត្វម្យ៉ាងដែលចំណាយពេលរស់នៅទឹកសាបតាំងពីតូចដល់ធំ ហើយចុះទៅពងកូននៅសមុទ្រនោះ ( ប្រភេទ Catadromous ) ត្រូវនេសាទបានយូរៗម្តង។ អ្នកនេសាទភាគច្រើនតែងប្រគល់វាទៅឱ្យសមត្ថកិច្ចជលផលសម្រាប់ការសិក្សា ដោយសារសាច់វាធុំក្លិនប្រ៉ម៉ខ្លាំង ពិបាកបរិភោគ ព្រោះទីទំនាបទឹកសាបដែលវារស់នៅស៊ីចំណីសំបូរទៅដោយប្លង់គុង។ ដោយឡែកសត្វផ្សោតក្បាលត្រងោល អាចសម្រប និងបន្សាំខ្លួនបាន ទាំងការរស់នៅស៊ីចំណី ទាំងការបន្តពូជនៅប្រព័ន្ធទឹកសាប ដែលធ្វើឱ្យពួកវានៅមានអត្ថិភាពរហូតមកដល់សព្វថ្ងៃនេះទោះជាពួកវាធ្លាប់រងការរំខានដោយឧស្សាហកម្មនេសាទជិត២សតវត្សកន្លងមកនិងការសម្លាប់រង្គាលនៅបឹងទន្លេសាបក្នុងរបបខ្មែរក្រហមដើម្បីចម្រាញ់យកខ្លាញ់ធ្វើជាប្រេងម៉ាស៊ីនកាណូតនេសាទ និងធ្លាប់ត្រូវបានយោធាបាញ់សម្លាប់លេងជាការកំសាន្តនៅតាមជំរករបស់ពួកវាក្នុងខេត្តស្ទឹងត្រែង និងក្រចេះក្នុងសង្គ្រាមនាទសវត្សឆ្នាំ៨០ក៏ដោយ ហើយជាពិសេសទៅទៀតគឺការប្រែប្រួលបរិស្ថានធម្មជាតិ និងធនធានមច្ឆជាតិ ដោយសារផលប៉ះពាល់ពីការអភិវឌ្ឍសាងសង់ទំនប់វារីអគ្គីសនីជាច្រើននៅក្នុងប្រព័ន្ធទន្លេមេគង្គផ្នែកខាងលើ ចាប់តាំងពីតំបន់ទីបេនៃប្រទេសចិន មកដល់ប្រទេសកម្ពុជានាពេលថ្មីៗនេះ។

## ៣. វិភាគទានរបស់ប្រព័ន្ធជលផលទឹកសាបកម្ពុជានៅបុរាណសម័យ

ការនាំមកនូវធនធានមច្ឆជាតិដោយប្រព័ន្ធទឹកសាបនៅកម្ពុជាកាលពី៤-៣ពាន់ឆ្នាំមុន បានទាក់ទាញការតាំងទីលំនៅរបស់មនុស្សជាតិ និងជួយជំរុញការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់មនុស្សជាតិឱ្យកាន់តែលឿនលឿនតាំងពីបុរេប្រវត្តិ រហូតមកដល់សម័យអង្គរដ៏រុងរឿង។ ជាភស្តុតាងចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន បានបង្ហាញយ៉ាងច្បាស់អំពីវិភាគទានដ៏ធំធេងរបស់ត្រីទឹកសាបទៅដល់ប្រជាជនខ្មែរនៅសម័យដ៏រុងរឿងនោះ។ ចម្លាក់ក៏បានបង្ហាញឲ្យឃើញពីរបៀបនិងបច្ចេកទេសនេសាទដែលជឿនលឿនដោយការប្រើឧបករណ៍សំណាញ់ និងឧបករណ៍ដែលអាចចាប់ត្រីបានច្រើនផ្សេងទៀត និងការកែ ច្នៃត្រីសម្រាប់រក្សាទុកបរិភោគរយៈពេលយូរ ដែលជនជាតិខ្មែរនៅតែរក្សាទំនៀមទំលាប់ទាំងនេះ រហូត ដល់បច្ចុប្បន្នកាល ដែលអាចបញ្ជាក់បានថា ត្រីទឹកសាបគឺជាមូលដ្ឋានម្ហូបអាហារដ៏សំខាន់របស់ជនជាតិខ្មែរ បន្ទាប់ពីស្រូវអង្ករ។ ការរីកចម្រើន និងភាពសម្បូរសប្បាយនៃទីក្រុងអង្គរធំនាសម័យនោះ បានទាក់ទាញឱ្យមានការធ្វើដំណើររបស់បរទេស ជាពិសេសជនជាតិចិន ទាំងមន្ត្រីរាជការ ទាំងអ្នកការទូត ទាំងអ្នកជំនួញ មកស្វែងយល់ការពិត និងមកធ្វើទំនាក់ទំនងចងស្ពានមេត្រីភាពជាមួយកម្ពុជា។

ទាក់ទងនឹងទស្សនកិច្ចបស់បរទេសនៅទីក្រុងអង្គរធំនេះ ពួកអ្នកប្រវត្តិសាស្ត្របានស្រាវជ្រាវរកឃើញឯកសារដែលសរសេរអំពីអរិយធម៌ខ្មែរនាពេលដែលរុងរឿងបំផុតនៃសម័យអង្គរ ដោយលោក ជីវ តាក្វាន់ ដែលជាមន្ត្រីរាជវាំងរបស់រាជវង្សម៉ាន់ជូនៃប្រទេសចិនដែលបានទទួលបេសកកម្មមកកម្ពុជាជាមួយក្រុមនាវិកសំពៅសមុទ្រអមដំណើរមន្ត្រីការទូតម្នាក់ទៀតដើម្បីមកចងស្ពានមេត្រីភាពជាមួយព្រះបាទឥន្ទ្រាវរ្ម័នទី៣នៃប្រទេសកម្ពុជា។ មន្ត្រីការទូត និងនាវិកចិនត្រូវបានទទួលការអនុញ្ញាតិឱ្យស្នាក់នៅក្នុងរាជវាំងចាប់តាំងពីពេលមកដល់នៅខែសីហាឆ្នាំ១២៩៦ រហូតដល់ខែកក្កដាឆ្នាំ១២៩៧។ ឯកសារខ្លះបានសរសេថា ដំណើរមកកម្ពុជារបស់លោក ជីវ តាក្វាន់ មិនមែនជាលើកទី១ទេ ហើយគាត់ក៏មិនមែនជាជនជាតិចិនទី១ និងមិនមែនជាអ្នកចុងក្រោយដែលបានមកដល់ប្រទេសនេះដែរតែគាត់ជាអ្នកទី១ដែលបានសរសេរអំពីអរិយធម៌ ប្រពៃណីទំនៀមទំលាប់ និងភាពសម្បូរបែបនៃត្រីនៅបឹងទន្លេសាប ដែលជាមូលដ្ឋានគ្រឹះនៃអត្ថិភាព និងឧត្តមភាពរបស់ប្រទេសកម្ពុជាដែលគាត់បានប្រសិទ្ធិនាមថា ជាព្រះរាជាណាចក្របន្ទាយមាស (Kingdom of Golden Tower) ឬដែនដីសុវណ្ណភូមិ[5]។ក្រោយពេលបានបកប្រែបោះពុម្ពផ្សាយនាចុងសតវត្សទី១៩ហើយនោះឯកសារនេះបានក្លាយទៅជាព័ត៌មានដ៏ទាក់ ទាញបំផុតសម្រាប់ប្រវត្តិវិទូ អ្នកស្រាវជ្រាវបុរាណវិទ្យា និងជាពិសេសអ្នកជំនួញចិនឱ្យមកធ្វើការស្វែងយល់ស្រាវជ្រាវនិងរកស៊ីនៅក្នុងឧស្សាហកម្មនេសាទដំបូងនៅកម្ពុជានាសម័យអាណានិគមបារាំង។

ភាពសម្បូរបែបនៃត្រីនៅបឹងទន្លេសាបបានជំរុញឱ្យខ្មែរបុរាណធ្វើការអភិវឌ្ឍបច្ចេកទេសកែច្នៃត្រីដែលជាដំបូងបង្អស់ធ្វើការផ្អើរត្រីដើម្បីងាយដឹកជញ្ជូនរក្សាទុកបានយូរជាពិសេសប្រើជាស្បៀងជាមួយបាយក្រៀមនៅពេលចេញទៅធ្វើសឹកសង្គ្រាមនៅទីឆ្ងាយ (សូមមើលរូបទី៦)។ ឯការកែច្នៃធ្វើប្រហុកក៏ប្រហែលជាអាចមានការពាក់ព័ន្ធជាមួយបច្ចេកទេសកែច្នៃដោយប្រើអំបិលប្រឡាក់ត្រី ហើយ ផ្អាប់ទុកប្រើប្រាស់រយៈពេលយូររបស់ជនជាតិចិននៅសម័យនោះដែលខ្មែរនៅជំនាន់នោះបានយកមកអភិវឌ្ឍកែខៃតម្រូវតាមការកែច្នៃត្រីល្អិតដ៏សម្បូរបែប ដែលធ្វើឱ្យប្រហុកក្លាយទៅជាម្ហូបអាហារមូលដ្ឋានបំផុតរបស់ជនជាតិខ្មែររហូត មកដល់បច្ចុប្បន្ននេះ។ វត្តមាននៃជនជាតិចិននៅពេលនោះ ក៏អាចជាការនាំយកមកប្រើផងដែរនូវបច្ចេកវិទ្យានេសាទបង់សំណាញ់ដោយប្រើសំណាញ់[6] ធ្វើអំពីសសៃធ្មៃ និងការប្រើសាច់អួន ឬសំណាញ់ជាឧបករណ៍ផ្សេងទៀតដែលអាចចាប់ត្រីបានច្រើន (សូមមើលរូបទី៥)។



រូបទី៥. បច្ចេកទេសនេសាទនៅសម័យអង្គរ



រូបទី៦. ការផ្អើរត្រីនៅសម័យអង្គរ



រូបទី៧. ត្រីគល់រាំងត្រូវបានចាត់ទុកជាត្រីទេព

[5] Chou Ta-Kuan, 1296. The Customs of Cambodia. Reprinted 1992
Chou Ta-Kuan: Apsara and Devata of Angkor Wat
Zhu Daguan, 1270 ? .....( born: 1266. Yongjia County, Whenzou, China; died:1346 ). A Record of Cambodia
Chou Ta Kuan’s excellent adventure
David Chandler, 1962. History of Cambodia

[6] បច្ចេកវិទ្យានេសាទដែលអាចនាំយកមកប្រើដោយបរទេសដែលអាចជាជនជាតិចិននៅអំឡុងសតវត្សទី១១ ឬទី១២ តែនៅលើពិភពលោកជនជាតិប៉ូលីណេស៊ី ជាអ្នកប្រើបច្ចេវិទ្យានេះមុនគេនៅកោះហាវ៉ៃ ក្នុងអំឡុងសតវត្សទី៤-៩ ) ។

ភស្តុតាងជាក់ស្តែងដែលបង្ហាញពីការទទួលស្គាល់តម្លៃដ៏ធំធេញនៃត្រីទឹកសាបនៅបឹងទន្លេសាបរបស់សង្គមខ្មែរនៅពេលនោះគឺចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាពិសេសជញ្ជាំងខាងត្បូងដែលពោរពេញទៅដោយចម្លាក់រូបត្រីប្រភេទសំខាន់ៗ និងវារីសត្វផ្សេងទៀតដូចជាអណ្តើក កន្ធាយ ក្រពើ ជាដើមដែលមានប្រយោជន៍ដល់ជីវភាពរស់នៅ និងសម្រាប់ប្រើប្រាស់ក្នុងកិច្ចការពារសត្រូវឈ្លានពាន។ ជនជាតិខ្មែរទាំងស្តេច ទាំងមន្ត្រី ទាំងប្រជាពលរដ្ឋនៅពេលនោះ បានទទួលស្គាល់ថាត្រីទឹកសាបនៅបឹងទន្លេសាបពិតជាបានផ្តល់វិភាគទានដ៏សម្បើមដល់សេដ្ឋកិច្ច-សង្គមកិច្ចជាតិ និងបានធ្វើឱ្យប្រទេសកម្ពុជា និងជនជាតិខ្មែរខ្លាំងក្លា ទើបកំណត់យកត្រីគល់រាំងដែលមានទំហំធំជាងគេនោះ ជាតំណាងត្រីទេពដែលត្រូវការពារ (សូមមើលរូបទី៧)។ អ្នកនេសាទនិងកសិករខ្មែរនៅបឹងទន្លេសាបនៅសម័យនោះ បានសាងសង់ផ្ទះខ្ពស់ផុតទឹកនៅរដូវទឹកតម្លើង ដើម្បីរស់នៅប្រកបរបរនេសាទ និងដាំស្រូវឡើងទឹក ឬស្រូវប្រដេញទឹក (ភូមិកំពង់ភ្លុក និងកំពង់ឃ្លាំងនៅខេត្តសៀមរាបនៅតែរក្សាស្ថានភាពនេះរហូតដល់បច្ចុប្បន្ន) ដែលអាចផ្គត់ផ្គង់ស្បៀងដល់ទីក្រុងអង្គរបានមួយចំណែកធំ។ ក្រោយសម័យអង្គរ ចាប់ពី សតវត្សទី១៣ រហូតមកដល់សម័យអាណានិគមបារាំងនាចុងសតវត្សទី១៩ អាណាចក្រខ្មែរបានធ្លាក់ក្នុងភាពកលយុគឥតឈប់ឈរដោយការបាក់បែកផ្ទៃក្នុង និងការរំលោភឈ្លានពានពីប្រទេសជិតខាង ដែលធ្វើឱ្យមានការផ្លាស់ប្តូររាជធានីជាច្រើនកន្លែង ដែលទោះជាយ៉ាងនេះក៏ដោយ ក៏ភាគច្រើននៃ រាជធានីទាំងនោះមានទីតាំងនៅ ជិតជាប់បឹងទន្លេសាប ដែលជាប្រភពសម្បូរត្រីសំរាប់គាំទ្រជីវភាពរស់នៅរបស់ប្រជាជននៅទីនោះ។ទាំងនេះគឺជាសក្ខីកម្មដែលមិនអាចបដិសេដបាននៃវិភាគទានរបស់ត្រីទឹកសាប ចំពោះម្ហូបអាហារជាចំណូលចិត្តនៃជនជាតិខ្មែរតាំងពីបូរាណសម័យមកដល់បច្ចុប្បន្នកាល។

ប្រវត្តិដ៏សំខាន់មួយទៀតទាក់ទងនឹងប្រពៃណីរបស់ជនជាតិខ្មែរ ជាពិសេសអ្នករស់នៅតំបន់ ដែលពុំសម្បូរត្រី (អ្នកស្រុកលើ) បាននាំគ្នាស្ទើរតែទាំងភូមិ (ក្រោយពេលច្រូតកាត់ប្រមូលផលស្រូវទុកដាក់ក្នុងជង្រុករួច) ធ្វើដំណើរតាមរទេះគោ-ក្របីចុះទៅបឹងទន្លេសាប ឬបឹងបួរដែលសម្បូរត្រីដែលនៅជិតបំផុត ដើម្បីទៅចាប់ត្រី (ធ្វើនេសាទគ្រួសារជាប្រពៃណី ឬបាចពង្រីង) ឬទិញត្រីយកមកកែឆ្នៃ ជាពិសេសកែឆ្នៃធ្វើប្រហុកទុកបរិភោគនៅពេលចុះធ្វើស្រែនៅរដូវវស្សាក្រោយ។មិនត្រឹមតែជនជាតិខ្មែរដែលរស់នៅភាគកណ្តាលប៉ុណ្ណោះទេ ជនជាតិខ្មែរនៅភាគខាងជើងដូចជា នៅខេត្តនគររាជ បូរីរ៉ាម ស៊ីសាកេត និងស៊ូរិន្ទជាដើម និងជនជាតិថៃនៅតំបន់ទាំងនោះក៏មានទម្លាប់ដូចគ្នានេះដែរ ដោយពួកគេបានលើកគ្នាធ្វើដំណើរតាមរទេះរាប់ពាន់គ្រឿងជារៀងរាល់ឆ្នាំ នៅដើមរដូវប្រាំងក្នុងខែមករា និងកុម្ភៈ ចុះមកតំបន់បាក់ព្រា ខេត្តបាត់ដំបង ដើម្បីចាប់ត្រីធ្វើប្រហុក និងត្រីកែច្នៃផ្សេងទៀតទុកសម្រាប់បរិភោគ នៅពេលចុះធ្វើស្រែនៅរដូវវស្សាក្រោយ។ តាមដែលដឹង តំបន់បាក់ព្រានេះគឺជាជង្រុកត្រីកំភ្លាញដ៏ធំបំផុតនៃបឹងទន្លេសាប ហើយងាយស្រួលចាប់នៅរដូវប្រាំង ដែលអាចជាការទាក់ទាញការចាប់អារម្មណ៍របស់អ្នកស្រុកលើទាំងនោះឱ្យចុះមកចាប់ត្រីធ្វើប្រហុកនៅទីនេះ ហើយក៏បានក្លាយជាប្រពៃណីរបស់អ្នកស្រុកលើទាំងនោះតាំងតែពីសម័យអង្គររហូតដល់ពេលច្រករបៀងតាមព្រំដែន ត្រូវបានបិទដោយអាជ្ញាធរខ្មែរ និងរដ្ឋបាលអាណានិគមនៅក្រោយឆ្នាំ១៩៤៥ (សូមមើលរូបទី៨) ទើបក្បួនរទេះអ្នកស្រុកលើ ទៅធ្វើប្រហុកនៅបាក់ព្រា បឹងទន្លេសាប ត្រូវបញ្ចប់ (Chevey et Le Poulin,1940)[7] ។

ដោយ ទូច ស៊ាងតាណា

*(នៅមានត)*

[7] CHEVEY, P. and LE POULIN, F., 1940. La Peche dans les Douces du Cambodge (5th Memory).
Publication: L’Institut Oceanographique de l’Indochine (Published under orientation of Armend KREMPF and Pierre CHEVEY).



# សមាជិកថ្មី
# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(**ក.ស.វ.**) សូមស្វាគមន៍យ៉ាងកក់ក្តៅ និងដោយសេចក្តីរីករាយចំពោះសមាជិកថ្មីរបស់**ក.ស.វ.** ឯកឧត្តម **ជួន សុភាន់ណារិទ្ធ** បច្ចុប្បន្នមានតួនាទីជាអនុរដ្ឋលេខា-ធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវតែងតាំងនិងផ្តល់ឋានៈ ឯកឧត្តម **ជួន សុភាន់ណារិទ្ធ** ជាសមាជិកនៃ**ក.ស.វ.** មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត/០៩២០/១០១៩ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។

ឯកឧត្តម **ជួន សុភាន់ណារិទ្ធ** ជាបញ្ញវន្តមួយរូបមានសញ្ញាបត្រវិស្វករមកពីប្រទេសបារាំង ជំនាញព័ត៌មានវិទ្យា(IT)។ ឯកឧត្តម ធ្លាប់បម្រើការងារនៅ IDS Group ជានាយកចាត់ចែង ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ២០២០ និងនៅ PARERA Group ជាអ្នកគ្រប់គ្រងផ្នែក IT ចាប់ពីឆ្នាំ១៩៨៩ ដល់ឆ្នាំ១៩៩៥។

តាមរយៈចំណេះដឹង និងបទពិសោធរបស់ ឯកឧត្តម **ជួន សុភាន់ណារិទ្ធ** **ក.ស.វ.** សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម នឹងចែករំលែកបទពិសោធន៍ ព្រមទាំងបំពេញភារកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលជាធាតុចូលដ៏សំខាន់ដល់ **ក.ស.វ.**។



ស្ពានមិត្តភាពកម្ពុជា-ជប៉ុន